# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១១-៨-២០០៩ -ព្រះរាជក្រម នស/រកម/០៨០៩/០១៤ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្ដីពីការផ្ទេរទណ្ឌិត ៦០៨២

១១-៨-២០០៩ -ព្រះរាជក្រម នស/រកម/០៨០៩/០១៥ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីវិស័យផ្លាស់ប្ដូរបាត្តពលកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ៦១០១


### ២~ព្រះរាជក្រឹត្យ


០៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៩១ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ,លោកស្រី,កញ្ញា និង អស់លោក ចំនួន ២០ រូប ៦១០៩

១១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨២០ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និង អស់លោកចំនួន៥៨រូប ៦១១១

១១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨២១ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និង អស់លោកចំនួន ៤៧ រូប ៦១១៣

១៣-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨២៣ ស្ដីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងស្ថាប័ន ចំនួន ០៨ រូប ៦១១៥

១៣-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨២៤ ស្ដីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងស្ថាប័ន ចំនួន ០៩ រូប ៦១១៨


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៣-៨-២០០៩ -អនុក្រឹត្យលេខ ១២៧ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៦១២១

១៣-៨-២០០៩ -អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៦១២៣

១៧-៨-២០០៩ -អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈវិស្វករកម្ពុជា ៦១២៦

១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦១៣១

១៩-៨-២០០៩ -អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពីការទទួលស្គាល់ការដាក់បញ្ចូលមន្ទីរពេទ្យសាកលវិទ្យាល័យអន្តរជាតិ សែនសុខ ស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យអន្តរជាតិ ៦១៣៣

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦១៣៥

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦១៣៦

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៦១៣៧

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៦៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិ ៦១៣៨

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៧០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៦១៤០

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៧១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦១៤១

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៧២ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦១៤២

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៣ អនក្រ.តត ស្តីពីការប្រគល់ និង ផ្ទេរភារកិច្ចជូនមន្ត្រីរាជការ ៦១៤៤

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៤ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦១៤៦

៣០-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦១៤៧

៣០-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១៤៨

៣០-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦១៤៩

៣១-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ៦១៥១

៣១-៧-២០០៩ -អនុក្រឹត្យលេខ ១២៧៩ អនក្រ.តត ស្តីពីការបញ្ចប់តំណែងមន្ត្រីរាជការ ៦១៥២

០៣-៨-២០០៩ -អនុក្រឹត្យលេខ ១២៨០ អនក្រ.តត ស្តីពីការបំពេញមុខងារជូនមន្ត្រីរាជការ ៦១៥៣

០៣-៨-២០០៩ -អនុក្រឹត្យលេខ ១២៨១ អនក្រ.តត ស្តីពីការបំពេញមុខងារជូនមន្ត្រីរាជការ ៦១៥៤


## ២_សេចក្តីសំរេច


០៥-៨-២០០៩ -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការតែងតាំងតំណែងជាតិសំរាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន ៦១៥៥

# គ

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១១-៨-២០០៩ -ប្រកាសលេខ ៧១៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិដស៊ី ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់ (កាត់ដេរ និង ប៉ាក់)" ៦១៥៧

១២-៨-២០០៩ -ប្រកាសលេខ ៧១៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង ផុង បង្កើតរោងចក្រ ផ្លាស្ទិក ៦១៦២

១២-៨-២០០៩ -ប្រកាសលេខ ៧១៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឃ្វីនធំ មេជើរ អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦១៦៧


### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន


១៤-៨-២០០៩ -ប្រកាសលេខ ៣៩៩ ប្រក.សកដជ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត ៦១៧២

១៤-៨-២០០៩ -ប្រកាសលេខ ៤០០ ប្រក.សកដជ ស្តីពីការបង្កើតក្រុមជំនាញត្រួតពិនិត្យលើយានដ្ឋានជួសជុល និង យានដ្ឋានកែច្នៃតម្លើងយានយន្ត ៦១៧៧


### ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍


០៥-៨-២០០៩ -ប្រកាសលេខ ១១២ ប្រក ស្តីពីការបង្កើតក្រុមការងារទេសចរណ៍ត្រួតពិនិត្យសកម្មភាពសេវាកម្មភ្នាក់ងារទេសចរណ៍ ៦១៨០


### ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៥-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១០២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីទ្រីមស៍ អេនជីនារិង ៦១៨២

២៥-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១០៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស ឌី ខេ អេនជីនារីង ៦១៨៤

២៥-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១០៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេម អ៊ី អេស ធី អ៊ីមផត អិចផត ៦១៨៦

២៥-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១០៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សិលា មាស អ៊ីមផត អិចផត ៦១៨៨

២៥-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១១៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ដូ ញុង អេឃ្វីបមេន ៦១៩០

# ឃ


២៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១៣២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បាយ័ន ស៊ីស្ទឹម** ៦១៩១

២៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១៣៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ឌី ឌី អេ-ស្ត្រាត់ធីរ៉េល អេនជី នារីង & ខនសាល់ធីង** ៦១៩៣

២៦-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦១៣៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី អិល ខេ អ៊ិនវេសមេន ខូ អិលធីឌី** ៦១៩៥

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាស្តីពីការផ្ទេរទណ្ឌិត

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ស្តីពីការផ្ទេរទណ្ឌិត ដែលធ្វើនៅញូវដែលី នាថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

នស/រកម.០៨០៩.០៣៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
ស ខេខ [illegible]

លេខ: ៧៦៤ ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# កិច្ចព្រមព្រៀង
# រវាង
# រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា
# ស្តីអំពីការផ្ទេរទណ្ឌិត

**រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាដែលហៅថា**
**"រដ្ឋភាគីលេខី"**

- **ដោយមានបំណង**ជួយសំរួលការស្តារនីតិសម្បទាសង្គមនៃទណ្ឌិតទាំងឡាយ នៅក្នុងប្រទេសរបស់ជនទាំងនោះ និង
- **ដោយបានពិចារណាឃើញថា** គោលបំណងនេះអាចសំរេចទៅបាន ដោយផ្តល់អោយជនបរទេសទាំងឡាយដែលត្រូវបានផ្តន្ទាទោស និងដាក់ទោសរួចហើយ ដោយសារការប្រព្រឹត្តបទល្មើសឧក្រិដ្ឋរបស់ជននោះ ដើម្បីមានឱកាសទៅទទួលទោសនៅក្នុងសង្គមរបស់ខ្លួន ។

**បានព្រមព្រៀងដូចតទៅ :**

## មាត្រា ១
## និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- **"ការវិនិច្ឆ័យ"** មានន័យថា ជាសេចក្តីសំរេច ឬ ជាដីកាបង្គាប់របស់តុលាការ ឬ របស់សាលាជំរះក្តី ដែលកំណត់ការដាក់ទណ្ឌកម្ម ។

ខ- **"រដ្ឋទទួល"** មានន័យថា ជារដ្ឋដែលមានទណ្ឌិតអាចត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេរ ដើម្បីឱ្យទណ្ឌិតនោះទទួលទោសបន្ត ។

គ- **"ការដាក់ទោស"** មានន័យថា ជាការដាក់ទណ្ឌកម្ម ឬ វិធានការណាមួយដែលពាក់ព័ន្ធដល់ការដក- ហូតសេរីភាពមានថេរវេលាកំណត់ ឬ ការដាក់ពន្ធនាគារអស់មួយជីវិតបង្គាប់ដោយតុលាការ ឬ សាលាជំរះក្តីក្នុងការអនុវត្តន៍យុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួន ។

ឃ- **"ទណ្ឌិត"** មានន័យថា ជាជនដែលកំពុងទទួលទោសឱ្យជាប់ពន្ធនាគារ ក្រោមដីកាបង្គាប់ដោយតុលាការព្រហ្មទណ្ឌ រួមមានតុលាការទាំងឡាយដែលត្រូវបង្កើតឡើងដោយច្បាប់សំរាប់រយៈពេលមួយ នៅក្នុងរដ្ឋភាគីលេខី ។

ង- "រដ្ឋផ្ទេរ" មានន័យថា ជារដ្ឋដែលបានដាក់ទោសទៅលើជនដែលអាចនឹងត្រូវបានផ្ទេរ ឬ ត្រូវបានផ្ទេររួចហើយ ។

## មាត្រា ២

## គោលការណ៍ទូទៅ

១- ជនណាដែលបានកាត់ទោសនៅក្នុងទឹកដីនៃរដ្ឋហត្ថលេខីមួយ អាចត្រូវបានផ្ទេរទៅកាន់ដែនដីនៃរដ្ឋហត្ថលេខីមួយទៀត ស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដើម្បីឱ្យជននោះទទួលទោសដែលបានដាក់ចំពោះខ្លួន ។ ចំពោះរឿងនេះ ជននោះអាចបញ្ជាក់ជូនរដ្ឋជាអ្នកផ្ទេរ ឬ រដ្ឋជាអ្នកទទួល នូវបំណងរបស់ខ្លួនអំពីការស្នើសុំផ្ទេរ ក្រោមកិច្ចព្រមព្រៀងនេះ ។

២- ការផ្ទេរខ្លួន អាចត្រូវបានស្នើឡើងដោយទណ្ឌិតណាមួយ ដែលជាជនជាតិនៃរដ្ឋហត្ថលេខី ឬ ដោយជនដទៃណាម្នាក់ដែលមានសិទ្ធស្នើសុំក្នុងនាមទណ្ឌិត ស្របទៅតាមច្បាប់នៃរដ្ឋហត្ថលេខី ដោយដាក់ពាក្យស្នើសុំទៅកាន់រដ្ឋហត្ថលេខី និងទៅតាមលំនាំដែលកំណត់ដោយរដ្ឋាភិបាលនៃរដ្ឋហត្ថលេខី ។

## មាត្រា ៣

## លក្ខខណ្ឌនៃការផ្ទេរទណ្ឌិត

១- ទណ្ឌិតអាចត្រូវបានផ្ទេរយោងទៅតាមកិច្ចព្រមព្រៀងនេះ តាមតែលក្ខខ័ណ្ឌដូចតទៅ:

ក- ទណ្ឌិតនោះជាសញ្ជាតិនៃរដ្ឋទទួល

ខ- ទណ្ឌិតនោះមិនត្រូវបានកាត់ទោសប្រហារជីវិត

គ- ការវិនិច្ឆ័យទោសរបស់តុលាការ ត្រូវបានចូលជាស្ថាពរ

ឃ- គ្មានការស៊ើបសួរ គ្មានការបើកសវនាការ ឬ នីតិវិធីណាផ្សេងទៀត ដែលត្រូវរង់ចាំយកមកអនុវត្តទៅលើទណ្ឌិត នៅក្នុងរដ្ឋជាអ្នកផ្ទេរ ។

ង- នៅពេលទទួលសំណើសុំផ្ទេរ ទណ្ឌិតត្រូវសល់ទោសយ៉ាងតិចបំផុត ៦ខែទៀត ឬ ត្រូវជាប់ពន្ធនាគារអស់មួយជីវិត

ច- សកម្មភាព ឬ ការខកខានមិនបានបំពេញកាតព្វកិច្ចដែលបណ្ដាលអោយជាប់ទោសនៅក្នុងរដ្ឋផ្ទេរ គឺជាអំពើ ដែលនាំអោយមានទោសឧក្រិដ្ឋនៅក្នុងរដ្ឋទទួល ឬ អាចជាបទល្មើសព្រហ្មទណ្ឌ ប្រសិនបើប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋទទួល ។

ឆ- ទណ្ឌិតមិនត្រូវបានកាត់ទោសពីបទល្មើសដោយច្បាប់យោធា

ជ- ការផ្ទេរការឃុំឃាំងទណ្ឌិតទៅអោយរដ្ឋទទួល មិនត្រូវធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ ឬ ផលប្រយោជន៍ណាមួយរបស់រដ្ឋផ្ទេរឡើយ

ឈ- ការយល់ព្រមផ្ទេរត្រូវមានការឯកភាពពីទណ្ឌិតនោះ ឬ ពីជនណាផ្សេង ដែលជាតំណាងស្របច្បាប់ យោងទៅតាមច្បាប់នៃរដ្ឋហត្ថលេខីនោះ ក្នុងករណីដែលទណ្ឌិតមានបញ្ហាអាយុ ឬ បញ្ហាកាយសម្បទា ឬ ជំងឺសរសៃប្រសាទដែលរដ្ឋហត្ថលេខី គិតថាចាំបាច់ ហើយ

ញ- រដ្ឋផ្ទេរ និង រដ្ឋទទួលត្រូវឯកភាពគ្នាចំពោះការផ្ទេរ ។

២- ក្នុងករណីពិសេស រដ្ឋផ្ទេរ និង រដ្ឋទទួល ក៏អាចសម្រុះសម្រួលគ្នាដើម្បីធ្វើការផ្ទេរទណ្ឌិត ទោះបីជា ថេរវេលាដែលនៅសេសសល់ដើម្បីទទួលទោសមានរយៈពេលតិចជាង ៦ខែ ក៏ដោយ ។

## មាត្រា ៤

## កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន

១- ប្រសិនបើទណ្ឌិតបានសំដែងបំណងចំពោះរដ្ឋជាអ្នកកាត់ទោស ចង់អោយមានការផ្ទេររូបខ្លួន សមស្របតាមកិច្ចព្រមព្រៀងនេះ រដ្ឋផ្ទេរត្រូវបញ្ជូនព័ត៌មាន និង ឯកសារដូចខាងក្រោមនេះ ទៅអោយរដ្ឋទទួល វៀរលែងតែរដ្ឋផ្ទេរ ឬ រដ្ឋទទួលបានសំរេចរួចទៅហើយថា គេមិនយល់ព្រម ចំពោះការផ្ទេរនោះទេ :

ក- ឈ្មោះ និង សញ្ជាតិ កាលបរិច្ឆេទ និង ទីកន្លែងកំណើតរបស់ទណ្ឌិត

ខ- អាស័យដ្ឋានរបស់ទណ្ឌិត ប្រសិនបើមាននៅក្នុងរដ្ឋទទួល

គ- របាយការណ៍ស្តីអំពីបទល្មើសដែលតម្រូវអោយដាក់ទណ្ឌកម្ម

ឃ- ប្រភេទ រយៈពេល និងកាលបរិច្ឆេទចាប់ផ្តើមនៃទោស

ង- ច្បាប់ចំលងនៃការវិនិច្ឆ័យដែលបញ្ជាក់ជាផ្លូវការ និង ច្បាប់ចំលងនៃបទបញ្ញត្តិរបស់ច្បាប់ពាក់ព័ន្ធ ដែលបានពោលយោងសំរាប់ផ្តន្ទាទោសទណ្ឌិត

ច- របាយការណ៍ផ្នែកវេជ្ជសាស្ត្រ សង្គម ឬព័ត៌មានទាក់ទងនានាស្តីពីទណ្ឌិត ទៅតាមតម្រូវការដើម្បីចាត់ការចំពោះពាក្យសុំរបស់ទណ្ឌិត ឬដើម្បីធ្វើការសំរេចលើប្រភេទនៃការឃុំឃាំងចំពោះទណ្ឌិត ។

ឆ- ព័ត៌មានដទៃទៀតដែលរដ្ឋទទួល អាចនឹងបញ្ជាក់ថាខ្លួនត្រូវការសំរាប់គ្រប់ករណី ដើម្បីអាចពិចារណាពីលទ្ធភាពទទួលយកការផ្ទេរ និង ផ្តល់ដំណឹងអោយទណ្ឌិតបានដឹងអំពីផលវិបាកនៃការផ្ទេរ ដោយអនុលោមតាមច្បាប់របស់ខ្លួន

ជ- សំណូមពរស្នើសុំផ្ទេរខ្លួនរបស់ទណ្ឌិត ឬ របស់ជនដែលមានសិទ្ធលើកសំណើក្នុងនាមទណ្ឌិត អនុលោមតាមច្បាប់របស់រដ្ឋផ្ទេរ និង

ឈ- របាយការណ៍ដែលបញ្ជាក់ពីរយៈពេលផ្តន្ទាទោសដែលទណ្ឌិតបានបំពេញរួចហើយ រួមទាំងពត៌មានស្តីពីការឃុំឃាំងមុនពេលបើកសវនាការ ការបន្ធូរបន្ថយទោស ឬ កត្តាដទៃផ្សេងៗ ទាក់ទងដល់ការ

អនុវត្តន៍ សាលក្រម ។

២- ក្នុងគោលបំណងជួយដល់ការធ្វើសេចក្តីសំរេចលើសំណូមពរតាមកិច្ចព្រមព្រៀងនេះ រដ្ឋទទួលត្រូវ បញ្ជូនពត៌មាន និង ឯកសារដូចតទៅនេះទៅអោយរដ្ឋផ្ទេរ វៀរលែងតែរដ្ឋទទួល ឬ រដ្ឋផ្ទេរបានសំរេចរួចហើយថា នឹងមិនយល់ព្រមចំពោះការផ្ទេរនោះទេ :

ក- សេចក្តីរៀបរាប់ ឬ ឯកសារដែលបញ្ជាក់ថាទណ្ឌិតជាសញ្ជាតិរបស់រដ្ឋទទួល

ខ- ច្បាប់ចំលងនៃច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួលដែលចែងពីសកម្មភាព ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដែលដោយសារហេតុផលនេះ ទើបមានការវិនិច្ឆ័យទោសនៅក្នុងរដ្ឋផ្ទេរ បើសកម្មភាព ឬ ការខកខានបំពេញកាតព្វកិច្ចនោះ ក៏ជាបទល្មើសយោងតាមច្បាប់របស់រដ្ឋទទួល ឬក៏អាចកំណត់ថាជាបទល្មើស ប្រសិនបើបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋទទួល

គ- សេចក្តីរៀបរាប់ពីអនុភាពរបស់ច្បាប់ ឬ បទបញ្ញត្តិដែលទាក់ទងនឹងរយៈពេលនិងការអនុវត្តន៍សាលក្រមនៅក្នុងរដ្ឋទទួលបន្ទាប់ពីការផ្ទេរខ្លួនទណ្ឌិត ហើយបើសិនជាអាចអនុវត្តបានត្រូវមានទាំងសេចក្តីរៀបរាប់ពីអនុភាពនៃវាក្យខ័ណ្ឌ ២ មាត្រា ៨ នៃកិច្ចព្រមព្រៀង នេះ ស្តីពីការផ្ទេរទណ្ឌិត

ឃ- ឆន្ទៈរបស់រដ្ឋទទួល ក្នុងការឯកភាពលើការផ្ទេរទណ្ឌិត និងការទទួលរាប់រងចាត់ចែងអនុវត្តទណ្ឌកម្ម ដែលនៅសេសសល់ចំពោះទណ្ឌិត និង

ង- ពត៌មាន និងឯកសារដទៃទៀត ដែលរដ្ឋផ្ទេរអាចយល់ឃើញថាជាការចាំបាច់ ។

## មាត្រា ៥

## សំណើសុំ និង ការឆ្លើយតប

១- សំណើសុំផ្ទេរទណ្ឌិតត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ តាមបែបបទដែលបានកំណត់រួចហើយ និង បញ្ជូនតាមរយៈអាជ្ញាធរកណ្តាលរបស់រដ្ឋជាអ្នកផ្ទេរ តាមផ្លូវការទូតទៅកាន់អាជ្ញាធរកណ្តាលរបស់រដ្ឋដែលត្រូវទទួល។ ការឆ្លើយតបត្រូវបញ្ជូនតាមបណ្តាញដូចគ្នានេះ ។

២- ចំពោះគោលបំណងនៃកថាខ័ណ្ឌទី ១ នៃមាត្រានេះ អាជ្ញាធរកណ្តាលរបស់ឥណ្ឌា គឺក្រសួងកិច្ចការផ្ទៃក្នុង និង អាជ្ញាធរកណ្តាលរបស់ប្រទេសកម្ពុជា គឺក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ។

៣- រដ្ឋដែលត្រូវបានគេស្នើសុំ ត្រូវផ្តល់ពត៌មានជាបន្ទាន់ទៅឱ្យរដ្ឋជាអ្នកស្នើអំពីការសំរេចរបស់ខ្លួន ថាតើយល់ព្រមឬក៏មិនយល់ព្រមចំពោះការផ្ទេរទណ្ឌិតនេះ ។

## មាត្រា ៦

## ការយល់ព្រម និង ការបញ្ជាក់ពីការយល់ព្រម

១- រដ្ឋផ្ទេរត្រូវធានាថា ការផ្ទេរនោះគឺធ្វើឡើងដោយមានការយល់ព្រមពីទណ្ឌិតចំពោះការផ្ទេរខ្លួន ដែលស្របតាមកថាខណ្ឌ ១ ចំណុច (ឃ) មាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយការយល់ដឹងពេញលេញ អំពីផលវិបាកនៃច្បាប់តទៅថ្ងៃក្រោយ ។ នីតិវិធីក្នុងការផ្តល់ការយល់ព្រមបែបនេះ នឹងត្រូវធ្វើទៅតាមច្បាប់របស់រដ្ឋផ្ទេរ ។

២- រដ្ឋផ្ទេរត្រូវផ្តល់ឱកាសអោយរដ្ឋជាអ្នកទទួលដើម្បីបានបញ្ជាក់ថា ការយល់ព្រមនោះត្រូវបានផ្តល់ឱ្យសមស្របទៅតាមល័ក្ខខ័ណ្ឌចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

## មាត្រា ៧-

## បច្ច័យនៃការផ្ទេរសំរាប់រដ្ឋទទួល

១- អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទទួលត្រូវបន្តអនុវត្តការដាក់ទណ្ឌកម្ម តាមរយៈការបញ្ជាផ្នែកតុលាការ ឬ ផ្នែករដ្ឋបាលតាមដែលច្បាប់ជាតិរបស់ខ្លួនតម្រូវ យោងទៅតាមល័ក្ខខ័ណ្ឌចែងក្នុងមាត្រា ៨ នៃកិច្ចព្រម ព្រៀងនេះ ។

២- ផ្អែកទៅលើបទបញ្ញត្តិចែងក្នុងមាត្រា ១០ នៃកិច្ចព្រមព្រៀងនេះ ការអនុវត្តដាក់ទណ្ឌកម្មនឹងត្រូវគ្រប់គ្រងដោយច្បាប់របស់រដ្ឋទទួល ហើយរដ្ឋនេះតែម្នាក់ឯងមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសំរេចសមស្របនានា ។

## មាត្រា ៨

## ការបន្តអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវអនុវត្តតាមចរិកគតិយុត្តិ និងទម្ងន់ទោស ដែលរដ្ឋផ្ទេរបានសំរេចហើយ ។

២- ទោះជាយ៉ាងណា បើសិនជាសាលក្រមមានចរិកគតិយុត្តិ និងទម្ងន់ទោស ឬ លក្ខណៈទាំងពីរប្រភេទនេះ មិនសមស្របទៅតាមច្បាប់របស់រដ្ឋទទួល ឬ ច្បាប់របស់រដ្ឋទទួលត្រូវការដូច្នោះ រដ្ឋនោះអាចយកលំនាំតាមសាលក្រម ឬ វិធានការដែលមានចែងក្នុងច្បាប់របស់ខ្លួន តាមបទបញ្ជាតុលាការ ឬ នីតិវិធីតាមផ្លូវរដ្ឋបាល ។ ដោយចរិកគតិយុត្តិ និង ទម្ងន់ទោសរបស់វា ការដាក់ទណ្ឌកម្ម ឬ វិធានការនានា ត្រូវធ្វើតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីអោយស៊ីគ្នាជាមួយនឹងការវិនិច្ឆ័យ ដែលរដ្ឋផ្ទេរបានសំរេចហើយ ។ ទោះបីយ៉ាងណា ដោយចរិកគតិយុត្តិ និង ទម្ងន់ទោសរបស់ខ្លួន រដ្ឋទទួលមិនត្រូវបន្ថែមស្ថានទម្ងន់ទោស ទៅលើសាលក្រមដែលត្រូវបានកំណត់រួចហើយនៅក្នុងរដ្ឋផ្ទេរឡើយ ។

## មាត្រា ៩

## បច្ច័យនៃការទទួលទោសចប់សព្វគ្រប់សំរាប់រដ្ឋផ្ទេរ

កាលណារដ្ឋទទួលបញ្ជាក់ប្រាប់រដ្ឋផ្ទេរតាមវាក្យខ័ណ្ឌ ១(ក) នៃមាត្រា១២ នៃកិច្ចព្រមព្រៀង នេះថាទោសត្រូវបានទទួលចប់សព្វគ្រប់ហើយ ការបញ្ជាក់បែបនេះមានប្រសិទ្ធិភាពនៃការរួចទោសនៅក្នុងរដ្ឋផ្ទេរហើយ ។

## មាត្រា ១០

## ការអនុគ្រោះទោស ការលើកលែងទោស ឬ ការប្តូរទោស និង បណ្តឹងសើរើចំពោះការវិនិច្ឆ័យ

១- រដ្ឋផ្ទេរទណ្ឌិត អាចនឹងសំរេចចំពោះពាក្យស្នើសុំអោយសើរើការវិនិច្ឆ័យ ។

២- រដ្ឋណាមួយនៃរដ្ឋហត្ថលេខី អាចផ្តល់ការអនុគ្រោះទោស ការលើកលែងទោស ឬ ការប្តូរទោស អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗរបស់ខ្លួន ។

## មាត្រា ១១

## ការបញ្ចប់ការអនុវត្តន៍សាលក្រម

រដ្ឋទទួលត្រូវបញ្ចប់ការអនុវត្តន៍សាលក្រមភ្លាម នៅពេលដែលបានទទួលព័ត៌មាន ពីរដ្ឋផ្ទេរ ស្តីពីការសំរេច ឬ វិធានការនានា ទាក់ទងទៅនឹងការបញ្ចប់ការអនុវត្តន៍សាលក្រម ។

## មាត្រា ១២

## ព័ត៌មានស្តីពីការអនុវត្តន៍សាលក្រម

១- រដ្ឋទទួលត្រូវបញ្ជាក់ជូនរដ្ឋផ្ទេរ :

ក- កាលណាការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ឬ

ខ- ប្រសិនបើទណ្ឌិតរត់ពីការឃុំឃាំងមុនពេលការអនុវត្តន៍សាលក្រមត្រូវបានបញ្ចប់ ក្នុងករណីបែបនេះ រដ្ឋទទួលត្រូវចាត់វិធានការចាប់ខ្លួនទណ្ឌិត និងដាក់ឱ្យទទួលខុសត្រូវពីការប្រព្រឹត្តបទល្មើសនេះ តាមច្បាប់ពាក់ព័ន្ធរបស់រដ្ឋទទួល ។

២- រដ្ឋទទួលត្រូវផ្តល់របាយការណ៍ពិសេសទាក់ទងទៅនឹងការអនុវត្តន៍សាលក្រម ប្រសិនបើរដ្ឋផ្ទេរមានស្នើសុំ ។

## មាត្រា ១៣

## ដំណើរឆ្លងកាត់

ប្រសិនបើរដ្ឋហត្ថលេខីណាមួយចាត់ការរៀបចំផ្ទេរទណ្ឌិតជាមួយរដ្ឋទីៗ រដ្ឋហត្ថលេខីមួយទៀត ត្រូវសហការដើម្បីសំរួលដំណើរឆ្លងកាត់ តាមរយៈទឹកដីនៃទណ្ឌិតដែលត្រូវបានផ្ទេរ លើកលែងតែរដ្ឋហត្ថលេខីមួយ ទៀតនោះ អាចបដិសេធការឆ្លងកាត់ចំពោះទណ្ឌិតណាដែលជាសញ្ជាតិរបស់ខ្លួន ។ រដ្ឋហត្ថលេខីដែលមានបំណងធ្វើការផ្ទេរបែបនេះ ត្រូវជូនដំណឹងជាមុនទៅរដ្ឋហត្ថលេខីមួយទៀត អំពីដំណើរឆ្លងកាត់បែបនេះ ។

## មាត្រា ១៤

### ការចំណាយ

រាល់ការចំណាយក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវជាបន្ទុករបស់រដ្ឋទទួល លើកលែងតែការចំណាយដោយឡែកផ្សេងៗនៅក្នុងទឹកដីរបស់រដ្ឋផ្ទេរ ។ យ៉ាងណាក៏ដោយ រដ្ឋទទួលស្វែងរកឱ្យមានការចំណាយទាំងស្រុង ឬជាចំណែកខ្លះពីទណ្ឌិត ឬ ពីប្រភពដទៃទៀត ។

## មាត្រា ១៥

### ការអនុវត្តន៍នៅលើទឹកដី

១- កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះ :

ក- សាធារណរដ្ឋឥណ្ឌា និង

ខ- ព្រះរាជាណាចក្រកម្ពុជា

ព្រមទាំងស្ថាប័ន និង អង្គភាពចំណុះទឹកដីរបស់រដ្ឋហត្ថលេខី ក៏ត្រូវបានបកស្រាយតាមបែបដូច្នេះដែរ ។

២- ការអនុវត្តន៍កិច្ចព្រមព្រៀងនេះចំពោះទឹកដីណាមួយ មានថេរវេលាយូរប៉ុន្មាន សមស្របទៅតាម វាក្យខ័ណ្ឌ ១ នៃមាត្រានេះ អាចនឹងត្រូវបញ្ចប់កាលណារដ្ឋហត្ថលេខីណាមួយផ្តល់ដំណឹងពីការអស់សុពលភាព ៦ខែ ជាមុនទៅអោយរដ្ឋហត្ថលេខីមួយទៀត តាមរយៈផ្លូវការទូត ។

## មាត្រា ១៦

### ភាសា

រាល់ការស្នើ និងឯកសារពាក់ព័ន្ធនានា ត្រូវធ្វើទំនាក់ទំនងជាភាសាអង់គ្លេស ។

## មាត្រា ១៧

### វិសាលភាពនៃការអនុវត្តន៍

កិច្ចព្រមព្រៀងនេះ ត្រូវបានយកទៅអនុវត្តលើចំពោះសាលក្រមដែលកំណត់រួចហើយ ទោះជាមុន ឬក្រោយពេលកិច្ចព្រមព្រៀងនេះ ចូលជាធរមានក៏ដោយ ។

## មាត្រា ១៨

### ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្ម ឬ ការកែតម្រូវលើកិច្ចព្រមព្រៀងនេះ ដែលបានឯកភាពដោយរដ្ឋហត្ថលេខីទាំងពីរ នឹងមានអនុភាពគតិយុត្តិ កាលណាមានការបញ្ជាក់ដោយការផ្លាស់ប្តូរកំណត់ទូត ។

## មាត្រា ១៩

## អវសានបញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន និងត្រូវចូលជាធរមាន នៅពេលដែលលិខិតតូបករណ៍ នៃការផ្តល់សច្ចាប័នត្រូវបានប្តូរគ្នា ។

២- កិច្ចព្រមព្រៀងនេះនឹងនៅតែមានអនុភាពគតិយុត្តិរហូតដល់ ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋហត្ថលេខីណាមួយ ផ្តល់សេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអោយរដ្ឋហត្ថលេខីមួយទៀត អំពីបំណងរបស់ខ្លួនដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៣- ដោយមិនចាំបាច់គិតគូរដល់ការបញ្ចប់ កិច្ចព្រមព្រៀងនេះនឹងបន្តអនុវត្តចំពោះការអនុវត្តនីដាក់ទណ្ឌកម្មទៅលើទណ្ឌិតដែលត្រូវបានផ្ទេរតាមកិច្ចព្រមព្រៀងនេះ រហូតដល់មុនកាលបរិច្ឆេទដែលការបញ្ចប់ត្រូវចូលជាធរមាន ។

ជាសក្ខីភាព អ្នកចុះហត្ថលេខាជាមន្ត្រីទទួលសិទ្ធិអំណាចត្រឹមត្រូវជាតំណាងរបស់រដ្ឋាភិបាលរៀងៗខ្លួន ត្រូវចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅញូដែលលី ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ជាពីរច្បាប់ដើម ភាសាខ្មែរ ហិណ្ឌី និងអង់គ្លេស គ្រប់អត្ថបទមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នាអត្ថបទជាភាសាអង់គ្លេស នឹងត្រូវប្រើជាអត្ថបទផ្លូវការ ។

**ជួសមុខអោយរាជរដ្ឋាភិបាលកម្ពុជា**

**ហោ ណាំហុង**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេសនិង**

**សហប្រតិបត្តិការអន្តរជាតិ**

**ជួសមុខអោយរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា**

( SHIVRAJ PATIL )

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

# *AGREEMENT BETWEEN THE ROYAL GOVERNMENT OF CAMBODIA AND THE GOVERNMENT OF THE REPUBLIC OF INDIA ON THE TRANSFER OF SENTENCED PERSONS*

*The Royal Government of Cambodia and the Government of the Republic of India hereinafter referred to as the Contracting States;*

***Desiring** to facilitate the social rehabilitation of sentenced persons into their own countries; and*

***Considering** that this objective should be fulfilled by giving foreigners, who have been convicted and sentenced as a result of their commission of a criminal offence, the opportunity to serve their sentences within their own society;*

*Have agreed as follows:*

## *ARTICLE 1*
## *Definitions*

*For the purpose of this Agreement:*

*( a ) "judgment" means a decision or order of a court or tribunal imposing a sentence;*

*( b ) "receiving State" means a State to which the sentenced person may be, or has been, transferred in order to serve his sentence;*

*( c ) "sentence" means any punishment or measure involving deprivation of liberty ordered by a court or tribunal for a determinate period of time or for life imprisonment, in the exercise of its criminal jurisdiction;*

*(d) "sentenced person" means a person undergoing a sentence of imprisonment under an order passed by a criminal court including the courts established under the law for the time being in force in the Contracting States;*

*( e ) "transferring State" means the State in which the sentence was imposed on the person who may be, or has been transferred.*

## *ARTICLE 2*
## *General Obligations*

*1. A person sentenced in the territory of one Contracting State may be transferred to the territory of other Contracting State in accordance with the provisions of this Agreement in order to serve the sentence imposed on him. To that end, he may express to the transferring State or the receiving State his willingness to be transferred under this Agreement.*

*2. Transfer may be requested by any sentenced person who is a national of a Contracting State or by any other person who is entitled to act on his behalf in accordance with the law of the Contracting State by making an application to the Contracting State and in the manner prescribed by the Government of that Contracting State.*

## *ARTICLE 3*
## *Conditions for transfer*

*A sentenced person may be transferred under this Agreement only on the following conditions:*

*(a) the person is a national of the receiving State;*

*(b) the death penalty has not been imposed on the sentenced person;*

*(c) the judgment is final;*

*(d) no inquiry, trial or any other proceeding is pending against the sentenced person in the transferring State;*

*(e) at the time of receipt of the request for transfer, the sentenced person still has at least six months of the sentence to serve or is undergoing a sentence of life imprisonment of the sentence is indeterminate;*

*(d) that the acts or omission for which that person was sentenced in the transferring State are those which are punishable as a crime in the receiving State, or would constitute a criminal offence if committed on its territory;*

*(g) the sentenced person has not been convicted for an offence under the military law;*

*(h) transfer of custody of the sentenced person to the receiving State shall not be prejudicial to the sovereignty, security or any other interest of the transferring State;*

*(i) consent to the transfer is given by the sentenced person or, where in view of his age or physical or mental condition either Contracting State considers it necessary, by any other person entitled to act on his behalf in accordance with the law of the Contracting State; and*

*(j) the transferring and receiving States agree to the transfer.*

*2. In exceptional cases, the transferring and receiving States may agree to a transfer even if the remaining period to be served by the sentenced person is less than six months.*

## *ARTICLE 4*
## *Obligation to furnish information*

*1. If the sentenced person has expressed an interest to the sentencing State in being transferred under this Agreement, the transferring State shall send the following information and documents to the receiving State unless either the receiving or the transferring State has already decided that it will not agree to the transfer:*

*(a) the name and nationality, date and place of birth of the sentenced person;*

*(b) his address, if any, in the receiving State;*

*(c) a statement of the facts upon which the sentence was based;*

*(d) the nature, duration and date of commencement of the sentence;*

*(e) a certified copy of the judgment and a copy of the relevant provisions of the law under which the sentence has been passed against the sentenced person;*

*(f) a medical, social or any other report on the sentenced person, where it is relevant for the disposal of his application or for deciding the*

*nature of his confinement;*

*(g) any other information which the receiving State may specify as required in all cases to enable it to consider the possibility of transfer and to enable it to inform the sentenced person of the full consequences of transfer for him under its law;*

*(h) the request of the sentenced person to be transferred or of a person entitled to act on his behalf in accordance with the law of the transferring State; and*

*(i) a statement indicating how much of the sentence has already been served, including information on any pre-trial detention, remission, or any other factor relevant to the enforcement of the sentence.*

*2. For the purposes of enabling a decision to be made on a request under this Agreement, the receiving State shall send the following information and documents to the transferring State unless either the receiving or the transferring State has already decided that it will not agree to the transfer:*

*(a) a statement or document indicating that the sentenced person is a national of the receiving State;*

*(b) a copy of the relevant law of the receiving State constituting the acts or omissions, on account of which the sentence has been passed in the transferring State, as if such acts or omissions were an offence under the law of the receiving State or would constitute an offence if committed on its territory;*

*(c) a statement of the effect of any law or regulation relating to the duration and enforcement of the sentence in the receiving State after the sentenced person's transfer including, if applicable, a statement of the effect of paragraph 2 of Article 8 of this Agreement on his transfer;*

*(d) the willingness of the receiving State to accept the transfer of the sentenced person and an undertaking to administer the remaining part of the sentence of the sentenced person; and*

*(e) any other information or document which the transferring State may consider necessary.*

### *ARTICLE 5*
### *Requests and replies*

*1. Requests for transfer shall be made in writing in the prescribed proforma, if any, and addressed through the central authority of the requesting State through diplomatic channels to the central authority of the requested State. Replies shall be communicated through the same channels.*

*2. For the purpose of paragraph 1 of this Article, the central authority shall be, in relation to India, the Ministry of Home Affairs and in relation to Cambodia, shall be the Ministry of Interior, Kingdom of Cambodia, Phnom Penh.*

*3. The requested State shall promptly inform the requesting State of its decision whether or not to agree to requested transfer.*

### *ARTICLE 6*
### *Consent and its verification*

*1. The transferring State shall ensure that the person required to give consent to the transfer in accordance with paragraph 1 (i) of Article 3 of this Agreement, does so voluntarily and with full knowledge of the legal consequences thereof. The procedure for giving such consent shall be governed by the law of the transferring State.*

*2. The transferring State shall afford an opportunity to the receiving State to verify that the consent is given in accordance with the conditions set out in paragraph 1 of this Article.*

### *ARTICLE 7*
### *Effect of transfer for the receiving State*

*1. The competent authorities of the receiving State shall continue the enforcement of the sentence through a court or administrative order, as may be required under its national law, under the conditions set out in Article 8 of this Agreement.*

*2. Subject to the provisions of Article 10 of this Agreement, the enforcement of the sentence shall be governed by the law of the receiving State and that State alone shall be competent to take all appropriate decisions.*

*ARTICLE 8*

*Continued enforcement of sentence*

*1. The receiving State shall be bound by the legal nature and duration of the sentence as determined by the transferring State.*

*2. If, however, the sentence is by its nature or duration or both incompatible with the law of the receiving State, or its law so requires, that State may, by court or administrative order, adapt the sentence to a punishment or measure prescribed by its own law. As to its nature and duration the punishment or measure shall, as far as possible, correspond with that imposed by the judgment of the transferring State. It shall, however not aggravate, by its nature or duration, the sentence imposed in the transferring State.*

*ARTICLE 9*

*Effect of completion of sentence for the transferring State*

*When the receiving State notifies the transferring State under paragraph 1 (a) of Article 12 of this Agreement that the sentence has been completed, such notification shall have the effect of discharging that sentence in the transferring State.*

*ARTICLE 10*

*Pardon, amnesty or commutation and review of judgment*

*(1) The transferring State alone shall decide on any application for the review of the judgment.*

*(2) Either of the Contracting States may grant pardon, amnesty or commutation of the sentence in accordance with its Constitution or other laws.*

*ARTICLE 11*

*Termination of enforcement of sentence*

*The receiving State shall terminate enforcement of the sentence as soon as it is informed by the transferring State of any decision or measure as a result of which the sentence ceases to be enforceable.*

*ARTICLE 12*

*Information on enforcement of sentence*

1. *The receiving State shall notify the transferring State:*

*(a) when the enforcement of the sentence has been completed; or*

*(b) if the sentenced person escapes from custody before enforcement of the sentence has been completed, in such cases the receiving State shall make every effort to have the prisoner arrested so that the prisoner be prosecuted for committing an offence under the relevant law of the receiving State on escape of prisoner.*

2. *The receiving State shall furnish a special report concerning the enforcement of the sentence, if so required by the transferring State.*

## *ARTICLE 13*
## *Transit*

*If either Contracting State enters into arrangements for the transfer of sentenced persons with any third State, the other Contracting State shall cooperate in facilitating the transit through its territory of the sentenced persons being transferred pursuant to such arrangements, except that it may refuse to grant transit to any sentenced person who is one of its own nationals. The Contracting State intending to make such a transfer shall give advance notice to the other Contracting State of such transit.*

## *ARTICLE 14*
## *Costs*

*Any costs incurred in the application of this Agreement shall be borne by the receiving State, except costs incurred exclusively in the territory of the transferring State. The receiving State may, however, seek to recover all or part of the costs of transfer from the sentenced person or from some other source.*

## *ARTICLE 15*
## *Territorial application*

*This Agreement shall apply;*

*(a) to the Republic of India; and*

*(b) to the Kingdom of Cambodia*

*and references to the territory of a Contracting State shall be construed accordingly.*

*2. The Application of this Agreement to any territory, in respect of which extension has been made in accordance with paragraph 1 of this Article, may be terminated upon expiry of six months' notice given by either Contracting State to the other through the diplomatic channels.*

*ARTICLE 16*
*Language*

*Requests and supporting documents shall be communicated in English.*

*ARTICLE 17*
*Scope of application*

*This Agreement shall be applicable to the enforcement of sentences imposed either before or after the entry into force of this Agreement.*

*ARTICLE 18*
*Amendments*

*Any amendments or modifications to this Agreement agreed by the Contracting States shall come into effect when confirmed by an Exchange of Diplomatic Notes.*

*ARTICLE 19*
*Final provisions*

*1. This Agreement shall be subject to ratification and shall enter into force on the date on which instruments of ratification are exchanged.*

*2. The Agreement shall continue to remain in force until six months from the date upon which either Contracting State gives written notice to the other Contracting State of its intention to terminate it.*

*3. Notwithstanding any termination, this Agreement shall continue to apply to the sentenced persons who have been transferred under this agreement before the date on which such termination takes effect.*

*In witness whereof the undersigned, being duly authorized thereto by their respective Governments, have signed this Agreement.*

*Done in duplicate at New Delhi on the 8th day of December, 2007 in the Khmer, Hindi and English languages, all texts being equally authentic. In case of differences in interpretation the English text shall prevail*

***For the Royal Government of Cambodia***

***(HOR Namhong)***
***Deputy Prime Minister, Minister of Foreign Affairs and International Cooperation***

***For the Government of the Republic of India***

***(Shivraj V. Patil)***
***Home Minister***

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្មរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគុយ៉ែត

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគុយ៉ែត ដែលបានចុះហត្ថលេខានៅទីក្រុងគុយ៉ែត នាថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥

នស/រកម.០៨០៥.០៣៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ហត្ថលេខា
ឋន សូក

លេខ: ៧៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# អនុស្សរណៈនៃការយោគយល់គ្នា

## ស្តីពី

## វិស័យផ្លាស់ប្តូរហត្ថពលកម្ម

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគុវ៉ែត

រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង រដ្ឋាភិបាលនៃរដ្ឋគុវ៉ែត ដែលតំណាងដោយ ក្រសួងសង្គមកិច្ច និងការងារ ចាប់ពីពេលនេះតទៅ ហៅថា " ភាគី "

ដោយបានកំណត់ច្បាស់លាស់ អំពីទំនាក់ទំនងជាមិត្តភាព រវាងរាជរដ្ឋាភិបាល និងពលរដ្ឋ នៃប្រទេសទាំងពីរ

ក្នុងបំណងបង្កើតទំនាក់ទំនងទ្វេភាគី ដោយឈរលើផលប្រយោជន៍ទៅវិញទៅមក រវាងគូភាគី

ក្នុងបំណងបង្កើនកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល ក្នុងវិស័យផ្លាស់ប្តូរហត្ថពលកម្ម

ភាគីទាំងពីរបានព្រមព្រៀងគ្នា:

### ប្រការ(១)

ពង្រឹងកិច្ចសហប្រតិបត្តិការក្នុង វិស័យ ការងារ និង មុខរបរ និង កិច្ចអភិវឌ្ឍន៍ហត្ថពលកម្ម ។

### ប្រការ(២)

បង្កភាពងាយស្រួលរាល់សេវានានា ដើម្បីអនុម័ត និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការបែបនេះ នៅក្នុងក្របខណ្ឌនៃច្បាប់ វិធាន និង បទបញ្ជាទាំងឡាយ ជាធរមាន ដែលអនុវត្តបាន របស់ប្រទេសទាំងពីរ ។

### ប្រការ(៣)

បង្កភាពងាយស្រួលរាល់ចលនា និងការនាំយកនូវ ហត្ថពលកម្មនៃជាតិរៀង១ខ្លួន ស្ថិតក្នុងក្របខណ្ឌនៃច្បាប់ វិធាន និងបទបញ្ជាទាំងឡាយ ជាធរមាន ដែលអាចអនុវត្តបាន របស់ប្រទេសនីមួយៗ ។

### ប្រការ(៤)

ផ្លាស់ប្តូរទស្សនកិច្ច និងកិច្ចពិគ្រោះយោបល់រវាងប្រទេសទាំងពីរ ផ្លាស់ប្តូរទេពកោសល្យ និងចំណេះធ្វើ នៅក្នុងវិស័យ នៃការបង្កើតឱកាសការងារ និងមុខរបរ ។

### ប្រការ(៥)

លក្ខខណ្ឌជាមូលដ្ឋាននៃមុខរបរ និងសិទ្ធិ និងភារកិច្ច របស់និយោជក និងនិយោជិក (កម្មករ) ត្រូវចែងឱ្យបានច្បាស់លាស់ក្នុងកិច្ចសន្យាការងារ ដោយស្របទៅតាមច្បាប់ និងបទបញ្ជា ដែលជាប់ទាក់ទងនៃប្រទេសម្ចាស់ផ្ទះ ។

### ប្រការ(៦)

និយោជកនៃប្រទេសម្ចាស់ផ្ទះ ត្រូវធានាអំពីការចេញប័ណ្ណការងារ ស្របទៅតាមឯកសារដែលបានដាក់ជូនដែល រួមមានទាំងកិច្ចសន្យាការងារមួយច្បាប់ផង នៅពេលស្នើសុំការសម្រេចទទួលយក ក្នុងរយៈពេល ពីរ (២)ខែ នៅពេល ដែលកម្មករទៅដល់ប្រទេសនេះ ។

### ប្រការ(៧)

ក្រុមការងាររួមមួយនឹងត្រូវបង្កើតឡើង ដើម្បីទទួលអនុវត្តកិច្ចការដូចតទៅ:

ក) ធានាការអនុវត្តអនុស្សរណៈនេះ

ខ) លើកសំណើសុំពិនិត្យមើលឡើងវិញអនុស្សរណៈនេះទៅតាមការចាំបាច់ និងដោះស្រាយរាល់បញ្ហា ឬការលំបាកនានា ក្នុងការអនុវត្តអនុស្សរណៈ និង

គ) សិក្សាអំពីលទ្ធភាពកើតមានឱកាសការងារ និងលើកអនុសាសន៍ ជាវិធានការណ៍នៃកិច្ចសហប្រតិបត្តិការបច្ចេកទេស ការបណ្តុះបណ្តាល ការពង្រឹងមុខជំនាញ និងការផ្តល់បុគ្គលិកជំនាញបច្ចេកទេស ទៅដល់គ្រប់ផ្នែក ដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់ភាគីទាំងពីរ ។

ក្រុមការងាររួមត្រូវជួបប្រជុំគ្នា ម្តងក្នុងមួយឆ្នាំ នៅប្រទេសណាមួយ តាមបែបប្តូរវេន និងតាមការចាំបាច់ តាមសំណើ របស់ភាគីណាមួយ ក្នុងចំណោមភាគីទាំងពីរ ។

ប្រការ(៨)

អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមានបញ្ញត្តិ ចាប់ពីកាលបរិច្ឆេទ ដែលភាគីណាមួយក្នុងចំណោមភាគីទាំង២បានជូនដំណឹងចុងក្រោយទៅភាគីមួយទៀត ស្របទៅតាមនីតិវិធីនៃច្បាប់ជាតិ ដែលបានតម្រូវនៅក្នុងការអនុវត្តនេះ ។

អនុស្សរណៈនៃការយោគយល់គ្នានេះ អាចនឹងត្រូវធ្វើវិសោធនកម្មបាន អាស្រ័យដោយការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ហើយវិសោធនកម្មនេះត្រូវធ្វើឡើងស្របទៅតាមនីតិវិធី ដែលបានកំណត់ក្នុងកថាខណ្ឌដំបូងនៃប្រការនេះ។

អនុស្សរណៈនៃការយោគយល់គ្នានេះមានសុពលភាពរយៈពេលបួន(៤)ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាពតទៅទៀត ជាស្វ័យប្រវត្តក្នុងរយៈពេលដូចគ្នា ឬក្នុងរយៈពេលណាមួយទៀត អាស្រ័យទៅតាមការស្នើសុំរបស់ភាគីណាមួយក្នុងចំណោមភាគីទាំង២ តាមរយៈការជូនដំណឹងតាមផ្លូវការទូត ទៅតាមបំណងបញ្ចប់របស់ភាគីនោះ ដោយសំណើនោះត្រូវធ្វើឡើងឱ្យបាន ប្រាំមួយ(៦)ខែ មុនកាលបរិច្ឆេត ដែលអនុស្សរណៈនេះ អស់សុពលភាព ។

បានចុះហត្ថលេខានៅ ទីក្រុងគូវ៉ែត នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ ជាពីរ(២)ច្បាប់ដើម ដែលក្នុងមួយច្បាប់ៗមានជាភាសាខ្មែរ អារ៉ាប់ និងអង់គ្លេស ហើយអត្ថបទទាំងអស់មានតម្លៃស្មើគ្នា។ ក្នុងករណី មានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវប្រើប្រាស់ជាឯកសារគោល។

| | |
|---|---|
| **តំណាងរាជរដ្ឋាភិបាលកម្ពុជា** | **តំណាងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត** |
| **ខង សូត** | **មេធាវី បាដឺ អេហ្វ. អាល់-ដូវៃឡា** |
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **ក្រសួងសង្គមកិច្ច និង ការងារ** |

# Memorandum of Understanding
on
The Field of Exchange of Manpower
between
The Royal Government of Cambodia
and
The Government of the State of Kuwait

The Royal Government of Cambodia represented by the Ministry of Labour and Vocational Training and the Government of the State of Kuwait represented by the Ministry of Social Affairs & Labour, hereinafter referred to as the "Parties";

Confirming the existing friendly relations between the governments and the people of both countries;

Desiring to establish bilateral relations based on mutual interest between them;

Desiring to promote cooperation and co-ordination in the field of exchange of manpower;

Both parties have agreed:

**Article (1)**

To strengthen cooperation in the field of labour and employment and manpower development;

**Article (2)**

To facilitate relevant services to adopt and develop such cooperation within the framework of the existing laws, rules and regulations of both countries.

## Article (3)

To facilitate the movement and bringing of manpower of their respective nationals within the framework of the existing applicable laws, rules and regulations in each country.

## Article (4)

To exchange visits and consultations between their countries, exchange of expertise and knowhow in the field of creating jobs and employment opportunities.

## Article (5)

The basic conditions of employment and the rights and duties of both the employer and the employee (worker) shall be specified in the contract of employment which shall be in line with the relevant laws and regulations of the host country.

## Article (6)

The employer in the host country shall issue the work permit along with the documents presented including a copy of the employment contract at the time of seeking approval within two months of the worker's arrival in the country.

## Article (7)

A Joint Working Group shall be constituted to carry out the following tasks:

a) To ensure the implementation of this Memorandum,
b) To propose revisions of the Memorandum as may be necessary and to resolve problems or difficulties in its implementation and
c) To study emerging employment opportunities and suggest measures of technical cooperation, training, skill enhancement and to provide all the sectors with technically skilled personnel for the mutual benefit of both parties.

The Joint Working Group shall meet once every year alternately in each of the countries and whenever necessary at the request of any one of the parties.

## Article (8)

This Memorandum of Understanding shall enter into force from the date of the last notification whereby one of the parties informs the other, that it has fulfilled the national legal procedures required for this implementation.

This Memorandum of Understanding can be amended with the consent of both parties and amendment will be effective according to the procedures mentioned in the previous paragraph of this article.

This Memorandum of Understanding shall be valid for a period of four years and will be renewed automatically for similar period or periods unless any of the two parties informs the other through diplomatic channels of its intention to terminate it, six months prior to its expiry.

Signed in Kuwait City on this 13th day of January 2009, in two originals, each in Arabic, Cambodia and English, all texts being equally authentic. In case of conflict in interpretation, the English text shall prevail.

| FOR THE ROYAL GOVERNMENT OF CAMBODIA | FOR THE GOVERNMENT OF THE STATE OF KUWAIT |
| --- | --- |
|  |  |
| **VONG SAUTH** | **Counsellor BADER F. AL-DOWAILA** |
| Minister of Labour and Vocational Training | Minister of Social Affairs and Labour |

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៩១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

១- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

- លោកជំទាវ **ណា នាង**
- លោកជំទាវ **ហ៊ូ ណារី**

២- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

- លោក **សេង គន្ធ**
- លោក **ណៃ ស៊ីថា**
- លោក **មៃ សៅរី**
- លោក **ចន ណារិទ្ធ**
- លោក **ម៉ែន សិរី**

៣-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

- លោក **ហ៊ាន រដ្ឋា**
- លោក **ទេព គូស៊ីប**
- លោក **មុំ វណ្ណា**
- កញ្ញា **ម៉ម សោភ័ណ**
- លោក **ឈៀក ហៀង**
- លោកស្រី **ខាត់ លីម**
- លោក **កែវ ឱណាម៉ូរ៉ា**
- លោក **ភា សៀ**



- លោក ព្រាំ សុខឿន
- លោក ហែម ខន
- លោក អ៊ឹង ចាន់គុណា
- លោកស្រី សាំង ផល្លាភ
- លោក គួ រដ្ឋា

៣៩ល.០៩០៨. ៩០២ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៧៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **ឈឹម ឌីណា**
២- លោក **សាំង ណន**
៣- វរសេនីយ៍ទោ **ឃួយ ត្រី**
៤- លោក **ទូច ផៃ**
៥- លោកជំទាវ **ម៉ាន់ ណាវី**
៦- លោក **ខួយ ឈើន**

ខ-គ្រឿងឥស្សរិយយស **មុនីសារភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម **មោគ សុធារិន**
២-លោកជំទាវ **ឆាយ គីម**
៣- លោក **ប៉ិច ផល្លា**

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១- លោក **មុយ បញ្ញារិទ្ធ**
២- អនុសេនីយ៍ឯក **សឿង ធុទ្ធី**
៣- លោក **ឯម ច័ន្ទមករា**
៤- លោក **សូ សុខប៊ុនថេត**
៥- លោក **ប៊ុន សារុំ**
៦- លោក **ងីង គីមម៉េង**

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **សេនា** ចំពោះ :

១- លោក **ឡុញ សុផល**
២- វរសេនីយ៍ទោ **លុញ ប្លង់**
៣-លោក **សូ សុខុន**
៤- លោក **ឃឹម សារ៉ោ**
៥- លោក **ប្រាក់ ចណ្ឌសេន**
៦- វរសេនីយ៍ទោ **ឯក សុខរ៉េត**
៧- លោក **ឌិន សុខ**
៨- លោក **ឆាយ យ៉ាត**
៩- លោក **ហង្ស ច័ន្ទរិទ្ធ**
១០- លោក **អ៊ួន សុចណ្ណារ៉ា**
១១- វរសេនីយ៍ទោ **វ៉ែន រិទ្ធី**
១២- អនុសេនីយ៍ឯក **ស៊ួន សត្ថាច័ន្ទ**
១៣-លោក **ដុំ គង់**
១៤- លោក **ឈើន ស៊ីធុំ**
១៥- លោក **ភិន សុភារក្ស**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ:

១- វរសេនីយ៍ត្រី អ៊ុម គែម
២- លោក ប៊ុច រី
៣- លោក គ្រួយ សេងហួង
៤- លោក ធេព សម្បត្តិ
៥- លោក យូ គីមសួន
៦- អនុសេនីយ៍ទោ អ៊ាម ចិន
៧- អនុសេនីយ៍ឯក ម៉ៅ សេរីវិបុល
៨- វរសេនីយ៍ត្រី គួល ស៊ីថា
៩- លោក យ៉ុន ចាន់
១០- លោក ឡុង គីមសួ
១១- លោក គ្រួច សម្បត្តិ
១២- លោក ជ៉ាន់ ប៉េងឡេង
១៣- លោក កែវ សុវណ្ណារា
១៤- លោក អ៊ុំ សាវុធ
១៥- លោក លឹម វណ្ណា
១៦- លោក អ៊ុង ជាហ៊ាង
១៧- លោក ណា សុធា
១៨- លោក ថាយ ប៊ុនថន
១៩- លោក ស្រី សាធឿន
២០- លោក រី ញ៉ី
២១- លោក សូ ខួយ
២២- លោក គីម ភាង
២៣- លោក ជួន សុផាត
២៤- លោក ឡេង យូសុង
២៥- អនុសេនីយ៍ឯក លន់ លាភ
២៦- លោក ជិន សីហា
២៧- លោក លី ហុង
២៨- លោក ពេជ្រ កែវមុនី

នស/រកត.០៨០៩.៩៣១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

លេខៈ ៧៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

| | |
|---|---|
| ១- ឯកឧត្តមឧត្តមសេនីយ៍ឯក **ទុំ សម្បូរ** | ២- ឯកឧត្តម **ហាត់ សុខមករា** |
| ៣- ឯកឧត្តម **គិត ទ្រី** | ៤- ឯកឧត្តម **ស៊ិន ឌុទ្ធី** |
| ៥- ឧត្តមសេនីយ៍ត្រី **ឡៅ សុខា** | ៦- លោក **យិន ម៉េង** |

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

| | |
|---|---|
| ១- លោក **យិន ម៉ោ** | ២- ឯកឧត្តមឧត្តមសេនីយ៍ឯក **ទួន សំអាន** |

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

| | |
|---|---|
| ១- ឯកឧត្តម **ជីវ សុខហាត់** | ២- លោក **សម ឌង** |

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

| | |
|---|---|
| ១- ឧត្តមសេនីយ៍ត្រី **ហាញ់ ច័រិង** | ២- ឯកឧត្តម **ម៉ត់ សម្បត្តិ** |
| ៣- លោក **ស៊ូ សុវណ្ណារ៉ា** | ៤- លោក **សំអុល ឆារិទ្ធ** |
| ៥- លោក **ថោង ប៉ូរ៉ាន់** | ៦- លោក **សុខ សុហេម៉ា** |
| ៧- លោក **ង៉ែ សុភាព** | ៨- លោក **ទួន គាយ** |
| ៩-លោក **លាង អូត** | ១០- វរសេនីយ៍ទោ **សេង រ៉ាឌុទ្ធ** |
| ១១- លោក **សុខ ចណ្ណា** | ១២- លោក **ម៉ៃ ជួន** |
| ១៣- លោក **ពេជ្រ គាយ** | ១៤- លោក **ប៉ែន សុណា** |
| ១៥- លោក **ផៃឌួន ផ្លាមគេសន** | ១៦-លោក **បាន បុត្តា** |

ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

១- Mr. YOSHITAKA KITAO

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តម អ៊ុំ ចណ្ណា ២- លោក ចឡុ ជាច

៣- លោកជំទាវ ម៉ិញ វិណាត ៤- លោក ឆា លឹមពិសិទ្ធ

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោកជំទាវ តាត តួច ២- វរសេនីយ៍ទោ ឡេង សុគិរៈ

៣- លោក ហឡុ សុគា ៤- លោក នួន សាម៉ន

៥- វរសេនីយ៍ទោ លី ហ៊ាច ៦- លោក ហ៊ួ ពៅ

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- ឯកឧត្តម ប៉ុ ម៉េចហុត ២- វរសេនីយ៍ទោ ព្រែត សុហាន

៣- វរសេនីយ៍ត្រី ស៊ុម សុផាន់ណា ៤- វរសេនីយ៍ត្រី នូ គីមលន

៥- វរសេនីយ៍ទោ ឃិន ខេមរា ៦- វរសេនីយ៍ទោ គឹម ថាយ

៧- លោក សុស សុផល ៨- វរសេនីយ៍ឯក នូ សុចណ្ណ

៩- វរសេនីយ៍ទោ ម៉ែន ខាន់ដារ៉ា ១០-អនុសេនីយ៍ឯក អ៊ុច ចណ្ណា

នសល.០៩០៨.៨៣២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩*

លេខ:៧៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩២៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងបរិស្ថាន** | | | | |
| ១ | **យឹម សំអឿន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | |
| ១ | **លឹម ស៊ីដេនីន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| **ក្រសួងព័ត៌មាន** | | | | |
| ១ | **ឈុំ សុជាតិ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងកិច្ចការនារី** | | | | |
| ១ | **អ៊ុង កន្ធាផាទី** | ស | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងផែនការ** | | | | |
| ១ | **ម៉ម ម៉ារ៉ាឌី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ២ :** ដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | | | | |
| [illegible] | [illegible] | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| **ក្រសួង[illegible]** | | | | |
| ១ | **[illegible] ចន្ទសុខា** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៣** : ដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដូចមានខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **ហ៊ី ធីរៈ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ **៧** | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ **៦** |

**មាត្រា ៤** : មន្ត្រីដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៣ ខាងលើត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នស/រកត.០៨០៩.៩៣៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៧៧៧.ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ៨ ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **ក្រសួងបរិស្ថាន** | | | | |
| ១ | **ឡុញ ចំរ៉ាល** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៧** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៦** |
| **ក្រសួងទេសចរណ៍** | | | | |
| ១ | **អ៊ុក ស៊ីផាន** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៥** |
| **ក្រសួងសុខាភិបាល** | | | | |
| ១ | **ង៉ូ យិនស៊ីម** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៤** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៥** |
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | | |
| ១ | **មាស សារុន** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៤** |
| ២ | **ឱក សុផុន** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៤** |
| **ក្រសួងផែនការ** | | | | |
| ១ | **ហ៊ូ ហួរ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៣** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៤** |
| ២ | **ឡូន ថាវរៈ** | ប | ពីវរមន្ត្រី ថ្នាក់លេខ **៧** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៦** |

**មាត្រា ២ :** ដំឡើងថ្នាក់ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល **តាមកម្រិតសញ្ញាប័ត្រ** ជូនមន្ត្រីក្រសួង **ផែនការ** ដូចមាននាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| [illegible] | **ទង្យ សាម៉ុន** | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ **៥** | ទៅឧត្តមមន្ត្រី ថ្នាក់លេខ **៤** |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

**មាត្រា ៣** : ដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| **ក្រសួងយុត្តិធម៌** | | | | |
|---|---|---|---|---|
| ១ | ជួន តេង | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

**មាត្រា ៤** : មន្ត្រីដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ២ ខាងលើត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

៣៧.០៩០៤.៩៤០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៤៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១៧៨ លានរៀល (មួយរយចិតសិបប្រាំបីលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) របស់មន្ទីរសុខាភិបាល ខេត្តស្វាយរៀងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយឧបត្ថម្ភស្បៀងអាហារអ្នកជម្ងឺ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:**- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួនប្រាំពីរ(០៧)កន្លែង ជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់អភិវឌ្ឍន៍ និងវិនិយោគ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ រួមមាន:

ក- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ **ពីរពាន់ បួនរយ សាមសិបពីរ (២.៤៣២) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូន

ក្រុមហ៊ុន អ៊ី សេង ខូ អិលធីឌី (Y SENG Co.,LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ១។

ខ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ "រាម" លើផ្ទៃដីទំហំ**មួយពាន់ បួនរយ ប្រាំបី (១.៤០៨) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រុមហ៊ុន ROYAL GROUP ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ធម្មជាតិ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ២។

គ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ **ប្រាំពាន់(៥.០០០)ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកែវសីមា ខេត្តមណ្ឌលគិរី សម្រាប់ផ្តល់ជូនក្រុមហ៊ុន ឫទ្ធី គិរី សីមា (RETTHY KIRI SEYMA Co.,Ltd) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកៅស៊ូ ដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៣។

ឃ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ **ប្រាំមួយពាន់ បួនរយ សាមសិបពីរ (៦.៤៣២)ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន ហួត សម្បត្តិ (HOUT SAMBAT Co.,LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៤។

ង- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ **ប្រាំមួយពាន់ បួនរយ ហាសិប (៦.៤៥០)ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន E-Investment Co.,LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៥។

ច- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីទំហំ **ប្រាំបួនពាន់ ប្រាំបួនរយ កៅសិបបី (៩.៩៩៣)ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ផ្តល់ជូនក្រុមហ៊ុន អាន ម៉ាឌី គ្រុប (AN MADY GROUP Co.,LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដាំដំណាំកៅស៊ូ និងប្រភេទឈើផ្សេងៗទៀត ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៦។

ឆ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ **មួយពាន់ ពីររយ ម្ភៃប្រាំ (១.២២៥) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូន ក្រុមហ៊ុន សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី (SAMNANG ANGKOR DEVELOPMENT LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៧។

**មាត្រា២: -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១២៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃគណៈវិស្វករកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- យោងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា លើកដំបូង អាណត្តិ ទី១ នាថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា ដែលសរសេរកាត់ថា "អគ្គលេខាធិការដ្ឋាន គ.វិ.ក." ។

## ជំពូកទី២

## ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន គ.វិ.ក. ទទួលបន្ទុកអនុវត្តភារកិច្ច តាមខ្លឹមសារមាត្រា ១៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា។

## ជំពូកទី៣

## រចនាសម្ព័ន្ធ និងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន គ.វិ.ក. ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន គ.វិ.ក. មានរចនាសម្ព័ន្ធដូចតទៅ ÷

- ផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកអប់រំ និងបណ្តុះបណ្តាល
- ផ្នែកចុះបញ្ជី គុណវុឌ្ឍិ ស្តង់ដារ ត្រួតពិនិត្យ និងទំនាក់ទំនងអន្តរជាតិ
- ផ្នែកនីតិកម្ម និងកោសល្យវិច័យ
- ផ្នែកបច្ចេកទេស និងសិក្សាស្រាវជ្រាវ
- ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.វិ.ក. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

អគ្គលេខាធិការដ្ឋាន គ.វិ.ក. អាចលើកសំណើកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនតាមការចាំបាច់។

**មាត្រា ៥.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានផ្នែក០១(មួយ)រូបអមដោយអនុប្រធានផ្នែកមួយចំនួនជាជំនួយការតាមការចាំបាច់។

ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន អនុប្រធានផ្នែកមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន គ.វិ.ក. មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន គ.វិ.ក. អាចមានមន្ត្រីជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងារ។ មន្ត្រីអគ្គលេខាធិការដ្ឋាន គ.វិ.ក. អាចទទួលប្រាក់ឧបត្ថម្ភផ្សេងៗក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍។

**មាត្រា ៧.-**

អគ្គលេខាធិការអាចស្នើទៅប្រធានក្រុមប្រឹក្សា គ.វិ.ក. ស្តីពីការតែងតាំងទីប្រឹក្សា សម្រាប់ផ្តល់យោបល់លើការងារបច្ចេកទេស ការងារច្បាប់ និងការងារផ្សេងៗ ដែលទាក់ទងនឹងវិជ្ជាជីវៈវិស្វកម្មតាមការចាំបាច់ ។

## ជំពូកទី៤
## ភារកិច្ចផ្នែកនីមួយៗ

**មាត្រា ៨.-**

ផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងការងាររដ្ឋបាល និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន គ.វិ.ក.
- រៀបចំផែនការសម្រាប់ដំណើរការ គ.វិ.ក.
- ស្វែងរកថវិកាដើម្បីធានានិរន្តរភាព គ.វិ.ក.
- គ្រប់គ្រងថវិកាចំណូលចំណាយរបស់ គ.វិ.ក.
- រៀបចំកិច្ចការហិរញ្ញវត្ថុ គម្រោងថវិកាប្រចាំឆ្នាំ និងផែនការឆ្នាំបន្តរបស់ គ.វិ.ក.
- ថែរក្សាទុកដាក់ឯកសារ បញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរបស់ គ.វិ.ក.
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពចំណូលចំណាយ និងសកម្មភាពការងាររបស់ គ.វិ.ក.
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ៩.-**

ផ្នែកអប់រំ និងបណ្តុះបណ្តាល មានភារកិច្ចដូចតទៅ ៖

- រៀបចំការបណ្តុះបណ្តាលបំពេញបន្ថែមសម្រាប់វិស្វករចុះបញ្ជី ដើម្បីក្លាយខ្លួនទៅជាបេក្ខជនវិស្វករអាជីព
- រៀបចំការបណ្តុះបណ្តាលបន្តសម្រាប់វិស្វករអាជីព គ.វិ.ក. ដើម្បីឱ្យមានគុណភាពស្របតាមការវិវត្តបច្ចេកវិទ្យាទំនើប
- ធ្វើសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សា វគ្គបំប៉នជំនាញ និង ការអប់រំក្រោយឧត្តមសិក្សា
- រៀបចំសិក្ខាសាលា វគ្គបំប៉នខ្លីៗទៅតាមមុខជំនាញដែលជាតម្រូវការរបស់សង្គម
- ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នសិក្សាវិស្វកម្ម និងបច្ចេកវិទ្យាអន្តរជាតិ ដើម្បីលើកកម្ពស់គុណភាពបញ្ញវន្តវិស្វករជាតិ
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់វិស្វករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈវិស្វកម្មឱ្យមានការទទួលស្គាល់ក្នុងក្របខ័ណ្ឌអាស៊ាន និងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ១០.-**

ផ្នែកចុះបញ្ជី គុណវុឌ្ឍិ ស្តង់ដារ ត្រួតពិនិត្យ និងទំនាក់ទំនងអន្តរជាតិ មានភារកិច្ចដូចតទៅ ៖

- ទទួលចុះបញ្ជីវិស្វករខ្មែរ និងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្មដោយជោគជ័យនៅតាម គ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- តាមដានត្រួតពិនិត្យឯកសាររបស់វិស្វករកម្ពុជា និងបរទេសក្នុងការប្រកបវិជ្ជាជីវៈវិស្វកម្ម
- រៀបចំបញ្ជីឈ្មោះវិស្វករដែលបានបញ្ចប់ការសិក្សាតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស្វកម្មនានា និងបញ្ជូនបញ្ជីឈ្មោះទៅក្នុងវគ្គបណ្តុះបណ្តាល ឬសម្រាប់ជាបេក្ខជនវិស្វករអាជីព គ.វិ.ក.
- វាយតម្លៃបេក្ខជនវិស្វករដែលបានដាក់ពាក្យចុះបញ្ជី ដើម្បីបំពេញលក្ខខណ្ឌជាវិស្វករអាជីព
- ជ្រើសរើស និងវាយតម្លៃលើបេក្ខភាពវិស្វករអាជីពកម្ពុជា ដើម្បីឱ្យទៅជាវិស្វករអាស៊ាន
- ធ្វើទំនាក់ទំនងអន្តរជាតិសម្រាប់គ្រប់ការងារវិស្វកម្ម
- ជាតំណាង គ.វិ.ក.ប្រចាំការនៅអគ្គលេខាធិការដ្ឋានអាស៊ាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ១១.-**

ផ្នែកនីតិកម្ម និងកោសល្យវិច័យ មានភារកិច្ចដូចតទៅ ÷

- រៀបចំបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌វិស្វករ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម
- ទទួលបណ្តឹង អំពីវិវាទដែលពាក់ព័ន្ធទៅនឹងវិស័យវិស្វកម្ម
- ការពារភាពស្របច្បាប់របស់វិស្វករ វិស្វករអាជីព និងវិស្វករអាស៊ានដែលបានចុះបញ្ជីនៅ គ.វិ.ក.
- ពិនិត្យ និងសិក្សារាល់អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យវិស្វកម្ម
- ធ្វើកោសល្យវិច័យលើការងារវិស្វកម្មរបស់វិស្វករអាជីពកម្ពុជា និងបរទេសដែលបានប្រកបវិជ្ជាជីវៈវិស្វកម្មក្នុងករណីមានវិវាទ
- វាយតម្លៃ និងបញ្ជាក់កម្រិតបច្ចេកទេសលើវិស័យវិស្វកម្ម
- តាមដានត្រួតពិនិត្យការអនុវត្តផែនការរបស់អគ្គលេខាធិការដ្ឋាន គ.វិ.ក.
- ចូលរួមរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្មតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ១២.-**

ផ្នែកបច្ចេកទេស និងសិក្សាស្រាវជ្រាវមានភារកិច្ចដូចតទៅ ÷

- ធ្វើទំនាក់ទំនង និងពិនិត្យបច្ចេកទេសការអនុវត្តគម្រោង ផលប៉ះពាល់សុខភាព សុវត្ថិភាព និងបរិស្ថាននៅពេលបំពេញភារកិច្ចរបស់វិស្វករកម្ពុជា និងបរទេសដែលបានចុះបញ្ជីនៅ គ.វិ.ក.
- សម្របសម្រួលផ្តល់យោបល់លើការអនុវត្តគម្រោងវិស្វកម្មក្នុងករណីមានភាពមិនប្រក្រតី
- សិក្សាស្រាវជ្រាវបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗក្នុង និងក្រៅប្រទេសលើវិស័យវិស្វកម្មដើម្បីនាំមកប្រើប្រាស់ និងផ្តល់ជូនវិស្វករកម្ពុជា និងបរទេស
- ផ្តល់ប្រឹក្សាបច្ចេកទេស ក្នុងនិងក្រៅប្រទេសលើវិស័យវិស្វកម្មកម្ពុជា

- រៀបចំស្តង់ដារវិស្វកម្ម ដើម្បីឱ្យមានការឯកភាពទូទាំងប្រទេស និងស្របតាមស្តង់ដារអាស៊ាន
- សិក្សាស្រាវជ្រាវចងក្រងសទ្ទានុក្រមបច្ចេកទេសវិស្វកម្មសម្រាប់ជំនួយដល់វិស្វករកម្ពុជា និងបរទេស
- រៀបចំ និងចូលរួមការសិក្សាស្រាវជ្រាវគម្រោងជាមួយវិស្វករកម្ពុជា និងបរទេស
- ធ្វើទំនាក់ទំនងជាតិ និងអន្តរជាតិសម្រាប់ការងារបច្ចេកទេស
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ១៣.-**

ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា មានភារកិច្ចដូចតទៅ ÷

- ផ្សព្វផ្សាយជាសាធារណៈរាល់សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម
- ផ្សព្វផ្សាយរបកគំហើញបច្ចេកវិទ្យាថ្មីៗដែលទាក់ទងនឹងវិស័យវិស្វកម្ម
- ចងក្រង បោះពុម្ពផ្សាយទស្សនាវដ្តីវិស្វកម្ម
- រៀបចំគេហទំព័រស្តីពីសកម្មភាពរបស់ គ.វិ.ក.
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ គ.វិ.ក.
- ស្រាវជ្រាវ និងប្រមូលព័ត៌មានវិស្វកម្មក្នុង និងក្រៅប្រទេស
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សា គ.វិ.ក. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ១៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក, ចុះថ្ងៃទិ ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅ របស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ៦៥០ លានរៀល ( ប្រាំមួយរយហាសិបលានរៀលគត់ ) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភធន និងជំនួយសង្គម) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២.-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្ដីជំរាបជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ..១៣១...អនក្រ-បក**

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ការដាក់បញ្ចូលមន្ទីរពេទ្យសាកលវិទ្យាល័យអន្តរជាតិសែនសុខ ស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យអន្តរជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអន្តរជាតិ
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១.-**

ទទួលស្គាល់ការដាក់បញ្ចូលមន្ទីរពេទ្យសាកលវិទ្យាល័យអន្តរជាតិសែនសុខ ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់សាកលវិទ្យាល័យអន្តរជាតិ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានអង្គភាព-ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការសាកលវិទ្យាល័យអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១២៦៧. អនក្រ-បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក **តូរុ ហុនដា** ( **Toru Honda** ) ប្រធានធិបតិអង្គការស្ពៃរកម្ពុជា ដែលបានជួយសាងសង់អគារមណ្ឌលសុខភាពសំរោង នៅក្នុងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃវែង ដោយប្រើថវិកាជំនួយរបស់អង្គការស្ពៃរកម្ពុជា សរុបចំនួន៦៩.៦៤០ ដុល្លារអាមេរិក។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៦៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនអស់លោក ចំនួន០៤រូប ដែលមានស្នាដៃចូលរួមចំណែកក្នុងការសាងសង់អគារមណ្ឌលសុខភាពសំរោង នៅក្នុងការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិព្រៃវែង ដោយប្រើថវិកាជំនួយរបស់អង្គការស្វែរកម្ពុជា សរុបចំនួន ៦៩.៦៤០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោកវេជ្ជបណ្ឌិត | **ពេជ្រ ហ៊ិន** | ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ២-លោក | **ធន់ ថុល** | ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃវែង |
| ៣-លោក | **ឃឹម គីឡេង** | អនុប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃវែង |
| ៤-លោក | **ហាស់ ហុន** | តំណាងសហគមន៍ ក្នុងឃុំសំរោង ស្រុកព្រៃវែង |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៦៧ - អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃចំនួន ០៣ នាក់ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **ឡឹក សារិទ្ធ** អត្តលេខ ០១៤៧២

២-លោកវរសេនីយ៍ទោ **ទ៉ាន់ កុសល** អត្តលេខ ០១៤៩១

៣-លោកវរសេនីយ៍ទោ **ជា ឡេង** អត្តលេខ ០១២៤៤ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ១៥៦៩ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែងនាយនគរបាលជាតិចំនួន ០២ នាក់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **ឌូ ខន** អត្តលេខ ០០៨៦ ពីប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

២-លោកវរសេនីយ៍ឯក **ហ៊ឹម យ៉ាន** អត្តលេខ ០២៣០៥ ពីអនុប្រធាន ទៅជាប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៧០ - អនក្រ-បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃចំនួន ០៣ នាក់ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **ឃួក ជា** អត្តលេខ ០២២៨៦
២-លោកវរសេនីយ៍ទោ **ហ៊ុល សម្បត្តិ** អត្តលេខ ០៣៦២៧
៣-លោកវរសេនីយ៍ទោ **ចេង សុខន្តី** អត្តលេខ ០១៦៨៧ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩ .
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៧១ . អនក្រ . បក

## អនុក្រឹត្យ
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូន ÷

១-លោកស្រី **ម៉ក់ សូនាង** អនុមន្ត្រីថ្នាក់លេខ៧ ឱ្យបំពេញមុខងារជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងផែនការ

២-លោកស្រី **អ៊ុច មុនីសេដ្ឋា** អនុមន្ត្រីថ្នាក់លេខ១០ ឱ្យបំពេញមុខងារជាអធិការ នៃអគ្គាធិការដ្ឋានក្រសួងផែនការ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩*

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៧៧២.អនក្រ-បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួនចំណុះវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូន÷

១-លោក **ម៉េង គីមហ៊ា** អនុមន្ត្រីថ្នាក់លេខ៩ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ។

២-លោក **ង៉ែត សុវណ្ណារ៉ូ** អនុមន្ត្រីថ្នាក់លេខ១១ ឱ្យបំពេញមុខងារជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងផែនការ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៧៣. អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ និងផ្ទេរភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួនចំណុះវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ និងផ្ទេរភារកិច្ចជូនមន្ត្រីរាជការរបស់ក្រសួងផែនការ ដូចមានរាយនាមខាងក្រោម÷

១-ប្រគល់ភារកិច្ចជូនលោក **ឡុង ជិនថា** អនុមន្ត្រីថ្នាក់លេខ៦ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ។

២-ផ្ទេរភារកិច្ចជូនលោក **លន់ គីមលាង** វរមន្ត្រីថ្នាក់លេខ១០ ពីអគ្គាធិការរង នៃអគ្គាធិការដ្ឋានទៅជាអគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៧៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែតម្រូវមាត្រា ១ និង មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការ បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

### ស ម្រេ ច

**មាត្រា ១** :ត្រូវបានប្រគល់ភារកិច្ចជូនលោក **ម៉ា នរិទ្ធ** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានព័ត៌មាននិងទំនាក់ទំនងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៧៥. អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនឯកឧត្តម **អ៊ឹស្វាងលី ឧស្វាន** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានសមាគមសាសនាដើម្បីអភិវឌ្ឍន៍បងប្អូនឥស្លាមនៃកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយសាងសង់អគារថ្មី ០២ខ្នង មាន១០បន្ទប់ ជួសជុលអគារចាស់ ០៦ខ្នង មាន៣០បន្ទប់ ធ្វើរបងព័ទ្ធជុំវិញវិទ្យាល័យ ប្រវែង ១.៩៤៤ ម៉ែត្រ និងផ្តល់ម៉ាស៊ីនដេរ ចំនួន២០គ្រឿង នៅវិទ្យាល័យព្រះបាទសុរាម្រិត ខេត្តកំពង់ឆ្នាំង ចំណាយអស់ថវិកា សរុបចំនួន ១៤០.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៧៦.អនក្រ.បត

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៤/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តតាកែវ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងដងទង់ សាលាពុទ្ធិកៈ និងសមិទ្ធផលនានា នៅវត្តប្រាង្គអណ្ដែត ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **មាឃ** | **ឈួន** | ចៅអធិការវត្តប្រាង្គអណ្ដែត | បច្ច័យ ១២.០០០ ដុល្លារ |
| ២-អ្នកស្រី | **សាន** | **សុខា** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកា ១២.៨០០ ដុល្លារ |
| ៣-លោកតា | **កុយ** | **ទី** | សប្បុរសជននៅអូស្ត្រាលី | ថវិកា ១២.៧៥០ ដុល្លារ |
| ៤-លោកយាយ | **តាំង** | **អូន** | សប្បុរសជននៅភ្នំពេញ | ថវិកា ១២.៦៥០ ដុល្លារ |
| ៥-លោកយាយ | **ម៉ែន** | **ឆែ** | សប្បុរសជននៅតាខ្មៅ | ថវិកា ១២.៥៥០ ដុល្លារ |
| ៦-លោកយាយ | **គង់** | **ផល** | សប្បុរសជននៅភ្នំពេញ | ថវិកា ១២.៣០០ ដុល្លារ |
| ៧-លោកគ្រូ | **សែម** | **អុន** | គ្រូបឋមសិក្សាប្រាង្គអណ្ដែត | ថវិកា ១២.១៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ ២០០៥

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៧៧. អនក្រ-បក**

# អនុក្រឹត្យ

## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០៤ រូប ឱ្យបំពេញមុខងារជា **អនុប្រធានរដ្ឋបាលព្រៃឈើ** មានឋានៈស្មើ **អគ្គនាយករង** ដូចមានរាយនាមខាងក្រោម :

១- លោក **ជា សំអាង**

២- លោក **អ៊ុំ សំអាត**

៣- លោក **ឆេង គឹមស៊ុន**

៤- លោក **សៀ វី**

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០៤ រូប ចំណុះរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានរាយនាមខាងក្រោម :

១- លោក **មាស មករា** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

២- លោក **ម៉ែន ភីមៀន** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចំរុះ

៣- លោក **ម៉ា សុខថា** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចំការព្រៃដាំ និងព្រៃឯកជន

៤- លោក **ទឹម ស៊ីថា** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៧៧ - អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វររសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនសព

-វរសេនីយ៍ទោ **នឹម នឹម** អត្តលេខ ០១៣៨១៨ នាយរងការិយាល័យសោធននិវត្តន៍ និងគោលនយោបាយ នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** [illegible] អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការបញ្ចប់តំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

## សម្រេច

**មាត្រា ១ :** ត្រូវបានបញ្ចប់តំណែង លោក **សេង យឿន** ពីអគ្គនាយករង នៃអគ្គនាយកដ្ឋានអធិការកិច្ច និង លុបឈ្មោះ លោក **សេង យឿន** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចេញពីក្របខណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជាស្ថាពរ ។

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៥៨០ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការបំពេញមុខងារជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១:** ត្រូវបានបំពេញមុខងារជូនលោក **ម៉ុម ណាជា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងសាធារណការ និងដឹកជញ្ជូន

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា "៣"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៤៨១ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការបំពេញមុខងារជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

### សម្រេច

**មាត្រា ១:** ត្រូវបានបំពេញមុខងារជូនលោក **គឹម សាន់** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងសាធារណការ និងដឹកជញ្ជូន

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា "៣"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧...សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងតំណាងជាតិសំរាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញធម្មនុញ្ញ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ច បន្ថែមលើមុខងារបច្ចុប្បន្ន ជូនឥស្សរជន ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និងឯកឧត្តម **កៅ គឹមហួន** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអ្នកជំនួស ក្នុងករណីអវត្តមាន ឯកឧត្តម តំណាងជាតិ ។

២-ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកជំនួស ក្នុងករណី អវត្តមាន ឯកឧត្តម តំណាងជាតិ ។

៣-ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាតំណាងជាតិ សំរាប់ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន និងឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកជំនួស ក្នុងករណីអវត្តមាន ឯកឧត្តម តំណាងជាតិ ។

**ប្រការ ២ :** តំណាងជាតិ នៃក្រុមប្រឹក្សាសហគមន៍ទាំងបីខាងលើ មានសិទ្ធិអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ក្រោមឱវាទនៅក្នុងសហគមន៍នីមួយៗមកចូលរួមប្រជុំ ដើម្បីសម្របសម្រួលការងារ របស់ក្រុមប្រឹក្សានោះ ។

**ប្រការ ៣ :** តំណាងជាតិ នៃក្រុមប្រឹក្សាសហគមន៍ទាំងបីខាងលើ អាចអញ្ជើញក្រសួង ឬស្ថាប័នពាក់ព័ន្ធ ក្រោមឱវាទនៅក្នុងសហគមន៍នីមួយៗទៅចូលរួមប្រជុំក្រុមប្រឹក្សាសហគមន៍អាស៊ាន ក្នុងករណីចាំបាច់ ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ និងប្រធាន គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១ និង៥
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ : ៧៦៥ ឧ.រ.ថ.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១៣៧៩/០៩ គ.វ.ក ចុះថ្ងៃទី៣០.០៦.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ិដស៍ ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១១.០៦.២០០៩

## សំរេច

**ប្រការ១** :

-អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិដស៍ ហ្គាមេន (ខេមបូឌា) តំណាងដោយ លោកស្រី LAU MUN CHEE ANGELA សញ្ជាតិចិន (ហុងកុង) អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ HA9050629 ចុះថ្ងៃទី០៧.០៩.២០០៤ មាន អាសយដ្ឋានបច្ចុប្បន្ន :Block 6, 23-B,Cavendish Heights, 33 Perkins Road. Jardine's Lookout, Hong Kong

ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូច ខាង ក្រោម :

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **សម្លៀកបំពាក់ ( កាត់ដេរ និងប៉ាក់)** | **៣២២០** |

-ផ្លាកឈ្មោះ រោងចក្រ :" **ស៊ីដស៍ ហ្គាមេន (ខេមបូឌា)** ( SEEDS GARMENT (CAMBODIA) CO., LTD.) "

-ទីតាំងរោងចក្រ :" ***អាគារ I នៃសួនឧស្សាហកម្មវឌ្ឍនៈ ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។***

**ប្រការ២** :

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣** :

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤** :

-ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥ :**

-ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

-ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

**ក.**ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

**ខ.**ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

**គ.**ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

-រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

-លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

-ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

ប្រកាសលេខ ១២៩០ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២០.១២.២០០៦ និង វិញ្ញាបនប័ត្រ លេខ ០០៩ ឧរថ .កឧ.បរ ចុះថ្ងៃទី២០.១២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខាទី៣ ដែលមានទីតាំងស្ថិតនៅ អាគារ "I" សួនឧស្សាហកម្មវឌ្ឍនៈផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:**

-អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៦:**

-ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-សាលារាជធានីភ្នំពេញ

" ដើម្បីជូនជ្រាប "

-ដូចប្រការ១៥ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៧៦២ ឧ.រ.ថ.ក.ឧ - ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១៦២៩/០៩ គ.វ.ក ចុះថ្ងៃទី២៧.០៧.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ៊ុង ផុង ចុះថ្ងៃទី២០.០៧.២០០៩

## ស ម្រេ ច

**ប្រការ១ :**

-អនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង ផុង តំណាងដោយ លោកស្រី រឿង ធារី សញ្ជាតិ ខ្មែរ អាយុ២៣ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណ ០២០៤៦៩៤៦៧ ចុះថ្ងៃទី៣០.០៣.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន : ភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាង ក្រោម :

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **ប្លាស្ទិក** | **៣៥៦០** |

-ផ្លាកឈ្មោះ រោងចក្រ ៈ **ហ៊ុង ផុង** ( HUNG PHONG CO., LTD.)

-ទីតាំងរោងចក្រ ៈ ***ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។***

**ប្រការ២ ៈ**

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ ៈ**

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ ៈ**

-ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥ :**

-ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

-ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម ៖

**ក.**ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

**ខ.**ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

**គ.**ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទ្វេងទាត់តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

-រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

-លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

-ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

-អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៥:**

-ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ-សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ១៤ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ : ៧១.៧ ឧ.ម.ថ.ក.រ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ២០៩១/០៦ គ.វ.ក ចុះថ្ងៃទី៣១.០៥.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឃ្វីនធី មេជើរ អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី២៩.០៧.២០០៩

## សំរេច

**ប្រការ១ :**

-អនុញ្ញាតឱ្យក្រុមហ៊ុន ឃ្វីនធី មេជើរ អ៊ិនដាសស្ទ្រៀល តំណាងដោយ លោកស្រី YANG HUANG, MEI-CHIN សញ្ជាតិចិន ( តៃវ៉ាន់) អាយុ៥៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131257221 ចុះថ្ងៃទី១៥.០២.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន : No.39, Wu Chuan 7th Road, wu-Kulnd. Zone Wu-Ku Hsiang, Taipei Hsien 248, តៃវ៉ាន់

Taiwan ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាង ក្រោម ៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **សម្លៀកបំពាក់** | **៣២២០** |

-ផ្លាកឈ្មោះ រោងចក្រ ៖ " **ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទៀល** ( QUINT MAJOR INDUSTRIAL CO., LTD.)

-ទីតាំងរោងចក្រ ៖ " ***ភូមិក្រយ៉ៅ-ភូមិក្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល*** " ។

**<u>ប្រការ២</u>** ៖

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**<u>ប្រការ៣</u>** ៖

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេង១ទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេង១ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**<u>ប្រការ៤</u>** ៖

-ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។/ ។

**ប្រការ៥ :**

-ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

-ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

-រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

-លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

-ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។៨

**ប្រការ១៤:**

-ប្រកាសលេខ ៧៥៦ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១១.០៧.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ឃ្វីនធំ មេជើរ អ៊ិនដាសស្ទ្រៀល ដែលមានទីតាំងស្ថិតនៅ ភូមិត្រយឹង-ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:**

- អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៦:**

- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "

-ដូចប្រការ១៥" ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ: ៣៩៤ ប.ក ...សកវដ

រាជធានីភ្នំពេញ ថ្ងៃទី១៤...ខែសីហា ឆ្នាំ 2009

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងការធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួង សាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## ស ម្រេ ច

**ប្រការ ១.-**

ជនជាតិខ្មែរ ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត ត្រូវបំពេញសំណុំបែបបទចុះបញ្ជី និងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត នៅអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន។ ចំពោះការសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មបើកសាខាសាលាបង្រៀនបើកបរយានយន្តនៅតាមបណ្តារាជធានី ខេត្ត ត្រូវធ្វើនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត នោះ ។

**ប្រការ ២.-**

អគ្គនាយកដ្ឋានដឹកជញ្ជូន មានភារកិច្ច គ្រប់គ្រង រៀបចំបែបបទចុះបញ្ជី និង ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាលាបង្រៀន បើកបរយានយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានភារកិច្ចគ្រប់គ្រង រៀបចំបែបបទចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាខាសាលា បង្រៀនបើកបរយានយន្តដែលមានអាសយដ្ឋាននៅក្នុងរាជធានី ខេត្តរបស់ខ្លួន។

**ប្រការ ៤.-**

អគ្គនាយកដ្ឋានដឹកជញ្ជូន មានភារកិច្ចរៀបចំបង្កើតក្រុមមន្ត្រីជំនាញ ធ្វើការត្រួតពិនិត្យ តាមដានគ្រប់សាលាបង្រៀនបើកបរយានយន្តនៅទូទាំងប្រទេស និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន ។

**ប្រការ ៥.-**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានភារកិច្ចរៀបចំបង្កើតក្រុមមន្ត្រីជំនាញ ធ្វើការត្រួតពិនិត្យតាមដានគ្រប់សាខាសាលាបង្រៀនបើកបរយានយន្ត ដែលមានអាសយដ្ឋានស្ថិតក្នុងរាជធានី ខេត្ត របស់ខ្លួន និងធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ ៦.-**

សំណុំបែបបទ សម្រាប់ដាក់ពាក្យសុំចុះបញ្ជីសាលាបង្រៀន និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត ឬសាខាសាលាបង្រៀនបើកបរយានយន្ត ត្រូវកំណត់ដូចខាងក្រោម :

| | |
|---|---|
| ១- ពាក្យសុំ មានបិទតែមប្រិយ៍សារពើពន្ធ ដូចឧបសម្ព័ន្ធ១ ឬ២ ឬ៤ | ១ច្បាប់ |
| ២- ប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ | ១ច្បាប់ |
| ៣-ប្រវត្តិរូបសង្ខេបរបស់ម្ចាស់មានបិទរូបថត | ១ច្បាប់ |
| ៤- ប្លង់ទីតាំងដែលមានការអនុញ្ញាតពីអាជ្ញាធរដែនដី | ១ច្បាប់ |
| ៥- បញ្ជីរាយនាមគ្រូបង្ហាត់ និងលិខិតបញ្ជាក់សមត្ថភាពគ្រូបង្ហាត់ | ១ច្បាប់ |
| ៦- ឈ្មោះសាលាបង្រៀនបើកបរយានយន្ត | ១ច្បាប់ |
| ៧- បញ្ជីប្រភេទយានយន្តដែលត្រូវយកមកបង្រៀន | ១ច្បាប់ |
| ៨- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនីមួយៗ | ១ច្បាប់ |
| ៩- លិខិតធានារ៉ាប់រងយានយន្តនីមួយៗ | ១ច្បាប់ |

១០- សំណុំឯកសារផ្សេងៗដែលពាក់ព័ន្ធ ។

ចំពោះការសុំអនុញ្ញាតធ្វើអាជីវកម្មសាខាសាលាបង្រៀនបើកបរយានយន្ត ត្រូវមានបន្ថែមនូវលិខិតចុះបញ្ជីសាលាបង្រៀនបើកបរយានយន្តមួយច្បាប់ និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តមួយច្បាប់ ។

**ប្រការ ៧.-**

ម្ចាស់សាលាបង្រៀនបើកបរយានយន្តត្រូវដាក់ពាក្យសុំបន្ត នៅពេលលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត អស់សុពលភាព ដូចឧបសម្ព័ន្ធ ៣ ឬ ៥។

**ប្រការ ៨.-**

សំណុំបែបបទ សម្រាប់ប្តូរទីតាំង ផ្ទេរ ឬលក់ ទៅឱ្យបុគ្គលផ្សេងទៀត ត្រូវកំណត់ដូចខាងក្រោម :

១- ពាក្យសុំប្តូរទីតាំងសាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត ដូចឧបសម្ព័ន្ធ៦ ឬ៨។

២- ពាក្យសុំផ្ទេរ ឬលក់អាជីវកម្មសាលាបង្រៀនបើកបរយានយន្ត ដូចឧបសម្ព័ន្ធ៧ ។

៣- សំណុំបែបបទ របស់ម្ចាស់ថ្មី ត្រូវកំណត់ ដូចក្នុងប្រការ ៦។

**ប្រការ ៩.-**

គំរូលិខិតចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត ត្រូវបានកំណត់ដូច ឧបសម្ព័ន្ធ ៩, ១០ និង១១ ។

លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត មួយច្បាប់កំណត់សម្រាប់សាលា ឬសាខា សាលាបង្រៀនបើកបរយានយន្ត តែមួយកន្លែងប៉ុណ្ណោះ ។

**ប្រការ ១០.-**

លិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត មានសុពលភាពប្រើប្រាស់រយៈពេល ៣ (បី) ឆ្នាំ ។ ម្ចាស់សាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មបន្ត ឡើងវិញទៀត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ យ៉ាងយូរបំផុតមុនពេលអស់សុពលភាព មកអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ។ ក្នុងរយៈពេលនេះ ម្ចាស់សាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត នៅតែមានសិទ្ធិបន្តធ្វើ សកម្មភាព រហូតដល់ថ្ងៃ ដែលអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត សម្រេចជាថ្មី ។

**ប្រការ ១១.-**

គ្រប់សាលា ឬសាខាសាលាបង្រៀនបើកបរយានយន្ត ត្រូវអនុវត្តកម្មវិធីសិក្សាទៅតាមប្រភេទយានយន្ត ដូចខាងក្រោម :

**១-ទោចក្រយានយន្តប្រភេទ ក១**

- **ផ្នែកទ្រឹស្តី (២០ ម៉ោង) :**

| | |
|---|---|
| - ច្បាប់ចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សញ្ញាចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ២ ម៉ោង |
| - សុវត្ថិភាពក្នុងការបើកបរ | ២ ម៉ោង |
| - បច្ចេកទេសទោចក្រយានយន្ត | ២ ម៉ោង |
| - ការសង្គ្រោះបឋម | ២ ម៉ោង |

- **ផ្នែកអនុវត្តបើកបរ (១០ ម៉ោង) :**

| | |
|---|---|
| - បច្ចេកទេសទោចក្រយានយន្ត | ១ ម៉ោង |
| - ការបើកបរទៅមុខត្រង់ និងជាន់ហ្វ្រាំងឈប់ | ១ ម៉ោង |
| - ការបើកបររាងធ្មេញរណា | ២ ម៉ោង |
| - ការបើកបរឡើងទួល និងចូលក្នុងផ្លូវកោង | ១ ម៉ោង |
| - ការបើកបររាងលេខ 8 | ១ ម៉ោង |
| - ការបើកបរលើផ្លូវលាត ការអនុវត្តន៍សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ៤ ម៉ោង |

**២-ទោចក្រយានយន្តប្រភេទ ក២**

- **ផ្នែកទ្រឹស្តី (២០ ម៉ោង) :**

| | |
|---|---|
| - ច្បាប់ចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សញ្ញាចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ២ ម៉ោង |
| - សុវត្ថិភាពក្នុងការបើកបរ | ២ ម៉ោង |
| - បច្ចេកទេសទោចក្រយានយន្ត | ២ ម៉ោង |
| - ការសង្គ្រោះបឋម | ២ ម៉ោង |

- **ផ្នែកអនុវត្តបើកបរ (១២ ម៉ោង) :**

| | |
|---|---|
| - បច្ចេកទេសទោចក្រយានយន្ត | ១ ម៉ោង |
| - ការបើកបរទៅមុខត្រង់ និងជាន់ហ្វ្រាំងឈប់ | ១ ម៉ោង |
| - ការបើកបររាងធ្មេញរណា | ២ ម៉ោង |
| - ការបើកបរឡើងទួល និងចូលក្នុងផ្លូវកោង | ១ ម៉ោង |
| - ការបើកបររាងលេខ 8 | ១ ម៉ោង |
| - ការបើកបរលើផ្លូវលាត ការអនុវត្តន៍សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ៦ ម៉ោង ។ |

**៣- រថយន្តប្រភេទ ខ**

- **ផ្នែកទ្រឹស្តី (២៦ ម៉ោង) :**

| | |
|---|---|
| - ច្បាប់ចរាចរណ៍ផ្លូវគោក | ៨ ម៉ោង |
| - សញ្ញាចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ២ ម៉ោង |
| - សុវត្ថិភាពក្នុងការបើកបរ | ៤ ម៉ោង |
| - បច្ចេកទេសរថយន្ត | ៤ ម៉ោង |
| - ការសង្គ្រោះបឋម | ២ ម៉ោង |

- **ផ្នែកអនុវត្តបើកបរ (៣០ ម៉ោង) :**

**៤- រថយន្តប្រភេទ គ**

- **ផ្នែកទ្រឹស្តី (២៤ ម៉ោង) :**

| | |
|---|---|
| - ច្បាប់ចរាចរណ៍ផ្លូវគោក | ៦ ម៉ោង |
| - សញ្ញាចរាចរណ៍ផ្លូវគោក | ៤ ម៉ោង |
| - សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ | ២ ម៉ោង |
| - សុវត្ថិភាពក្នុងការបើកបរ | ៤ ម៉ោង |
| - បច្ចេកទេសរថយន្ត | ៤ ម៉ោង |
| - ការសង្គ្រោះបឋម | ២ ម៉ោង |
| - ការផ្ទុកទំនិញ | ២ ម៉ោង |

- **ផ្នែកអនុវត្តបើកបរ (៣៥ ម៉ោង) :**

- បច្ចេកទេសរថយន្ត ២ ម៉ោង
- ការបើកបរទៅមុខ និងថយក្រោយត្រង់ ២ ម៉ោង
- ការបើកបរឡើងទួល ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង S ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង Z ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង T ២ ម៉ោង
- ការចតស្របរាង P ២ ម៉ោង
- ការចតទទឹងរាង U ២ ម៉ោង
- ការបើកបរលើផ្លូវលាត ការអនុវត្តន៏សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ១៤ ម៉ោង ។

- បច្ចេកទេសរថយន្ត ២ ម៉ោង
- ការបើកបរទៅមុខ និងថយក្រោយត្រង់ ២ ម៉ោង
- ការបើកបរឡើងទួល ២ ម៉ោង
- ច្រកចេញ និងចូលច្រកផ្លូវតូច ៦ ម៉ោង
- ការចតស្រប ៣ ម៉ោង
- ការបើកបរលើផ្លូវលាត ការអនុវត្តន៏សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២០ ម៉ោង ។

### ៥. រថយន្តប្រភេទ ឃ១

**• ផ្នែកទ្រឹស្តី ( ២០ ម៉ោង ) :**

- ច្បាប់ចរាចរណ៍ផ្លូវគោក ៦ ម៉ោង
- សញ្ញាចរាចរណ៍ផ្លូវគោក ៤ ម៉ោង
- សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២ ម៉ោង
- សុវត្ថិភាពក្នុងការបើកបរ ២ ម៉ោង
- បច្ចេកទេសរថយន្ត ២ ម៉ោង
- ការសង្គ្រោះបឋម ២ ម៉ោង
- ការដឹកអ្នកដំណើរ ២ ម៉ោង

**• ផ្នែកអនុវត្តបើកបរ ( ៣០ ម៉ោង ) :**

- បច្ចេកទេសរថយន្ត ២ ម៉ោង
- ការបើកបរទៅមុខ និងថយក្រោយត្រង់ ២ ម៉ោង
- ការបើកបរឡើងទួល ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង S ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង Z ២ ម៉ោង
- ការបើកបរលើផ្លូវចង្អៀតរាង T ២ ម៉ោង
- ការចតស្របរាង P ២ ម៉ោង
- ការចតទទឹងរាង U ២ ម៉ោង
- ការបើកបរលើផ្លូវលាត ការអនុវត្តនសញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ១៤ ម៉ោង ។

### ៦. រថយន្តប្រភេទ ឃ២

**• ផ្នែកទ្រឹស្តី ( ២៤ ម៉ោង ) :**

- ច្បាប់ចរាចរណ៍ផ្លូវគោក ៦ ម៉ោង
- សញ្ញាចរាចរណ៍ផ្លូវគោក ៤ ម៉ោង
- សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២ ម៉ោង
- សុវត្ថិភាពក្នុងការបើកបរ ៤ ម៉ោង
- បច្ចេកទេសរថយន្ត ៤ ម៉ោង
- ការសង្គ្រោះបឋម ២ ម៉ោង
- ការដឹកអ្នកដំណើរ ២ ម៉ោង

**• ផ្នែកអនុវត្តបើកបរ ( ៣៥ ម៉ោង ) :**

- បច្ចេកទេសរថយន្ត ២ ម៉ោង
- ការបើកបរទៅមុខ និងថយក្រោយត្រង់ ២ ម៉ោង
- ការបើកបរឡើងទួល ២ ម៉ោង
- ច្រកចេញ និងចូលច្រកផ្លូវតូច ៦ ម៉ោង
- ការចតស្រប ៣ ម៉ោង
- ការបើកបរលើផ្លូវលាត ការអនុវត្តន៏សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២០ ម៉ោង ។

### ៧. រថយន្តប្រភេទ ខ (ខខ ខគ ខឃ១និងខឃ២)

**ផ្នែកទ្រឹស្តី ( ២៤ ម៉ោង )**

- ច្បាប់ចរាចរណ៍ផ្លូវគោក ៦ ម៉ោង
- សញ្ញាចរាចរណ៍ផ្លូវគោក ៤ ម៉ោង
- សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២ ម៉ោង
- សុវត្ថិភាពក្នុងការបើកបរ ៤ ម៉ោង
- បច្ចេកទេសរថយន្ត ៤ ម៉ោង
- ការសង្គ្រោះបឋម ២ ម៉ោង
- ការផ្ទុកសណ្តោង ២ ម៉ោង

### រថយន្តប្រភេទ ខ (ខខ ខគ ខឃ១និងខឃ២)

**• ផ្នែកអនុវត្តបើកបរ ( ៣៥ ម៉ោង ) :**

- បច្ចេកទេសរថយន្តសណ្តោង ២ ម៉ោង
- ការបើកបរទៅមុខ និងថយក្រោយត្រង់ ២ ម៉ោង
- ការបើកបរឡើងទួល ២ ម៉ោង
- ច្រកចេញ និងចូលច្រកផ្លូវតូច ៦ ម៉ោង
- ការចតស្រប ៣ ម៉ោង
- ការបើកបរលើផ្លូវលាត ការអនុវត្តន៏សញ្ញាចរាចរណ៍ និងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ២០ ម៉ោង ។

**ប្រការ ១២.-**

ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវធ្វើការណែនាំបញ្ចូលកម្មវិធីសិក្សាអំពីការអនុវត្តន៍បើកបរតាមប្រព័ន្ធកំព្យូទ័រ(Driving Simulator) មុននឹងចូលកម្មវិធីអនុវត្តបើកបរលើផ្លូវផ្ទាល់ ។ ចំពោះសៀវភៅ និងឯកសារដែលសាលាត្រូវយកមកបង្រៀន ត្រូវមានការត្រួតពិនិត្យ និងបញ្ជាក់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូន ។

**ប្រការ ១៣.-**

គ្រប់រថយន្តដែលត្រូវយកមកបង្រៀនបើកបរត្រូវមានប្រព័ន្ធបញ្ជាហ្រ្វាំងជើង ២ មួយសំរាប់សិស្ស មួយទៀតសំរាប់គ្រូបង្ហាត់។ យានយន្តដែលយកមកបង្រៀនសិស្សត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសក្នុងរយៈពេលមួយឆ្នាំម្ដង និងត្រូវទិញលិខិតធានារ៉ាប់រងតតិយជនជារៀងរាល់ឆ្នាំ ។ ចំពោះសញ្ញាសំគាល់រថយន្តដែលត្រូវយកបង្រៀន ត្រូវកំណត់ទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន ។

**ប្រការ ១៤.-**

គ្រប់សាលា ឬសាខាសាលាបង្រៀនបើកបរយានយន្តត្រូវមានបន្ទប់សំរាប់បង្រៀនទ្រឹស្ដី និងទីកន្លែងសំរាប់បង្រៀនបើកបរយានយន្តឱ្យបានសមរម្យ និងមានបង្អួចមានទ្វារខ្យល់ចេញចូលគ្រប់គ្រាន់ ។

**ប្រការ ១៥.-**

គ្រប់សាលាបង្រៀនបើកបរយានយន្តដែលមានច្បាប់អនុញ្ញាតរួចហើយ មិនចាំបាច់ធ្វើការចុះបញ្ជីជាថ្មីឡើយ ប៉ុន្តែត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅអគ្គនាយកដ្ឋានដឹកជញ្ជូន។ ក្នុងករណីសាលាបង្រៀនបើកបរយានយន្តដែលត្រូវបើកថ្មី ត្រូវដាក់ពាក្យសុំចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅអគ្គនាយកដ្ឋានដឹកជញ្ជូន។ ចំពោះសាខាសាលាបង្រៀនបើកបរយានយន្តដែលមានច្បាប់អនុញ្ញាតរួចហើយ និងសុំបើកថ្មី ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅមន្ទីរសាធារណការ-និងដឹកជញ្ជូនរាជធានី ខេត្ត ។

**ប្រការ ១៦.-**

គ្រូបង្ហាត់បង្រៀននៅតាមសាលាបង្រៀនបើកបរនៅពេលកំពុងបង្ហាត់បង្រៀន ត្រូវស្លៀកពាក់ឯកសណ្ឋានដែលមានចែងក្នុងសេចក្ដីណែនាំរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន ។

**ប្រការ ១៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៨.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកដឹកជញ្ជូន និងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវអនុវត្ត តាមភារកិច្ចរៀង ៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- គ្រប់សាលាបង្រៀនបើកបរយានយន្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ១៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ត្រាំ អ៊ីវទឹក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF PUBLIC WORKS AND TRANSPORT

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ : ៥៧០ / ឋ.ក....សក.ចរ

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែសីហា ឆ្នាំ 2009

**ប្រកាស**

**ស្តីពី**

**ការបង្កើតក្រុមមន្ត្រីជំនាញត្រួតពិនិត្យលើយានដ្ឋានជួសជុល**
**និងយានដ្ឋានកែឆ្នៃតម្លើងយានយន្ត**

.....................................

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែឆ្នៃតម្លើងយានយន្ត
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និតដឹកជញ្ជូន

**សម្រេច**

**ប្រការ ១** : បង្កើតក្រុមមន្ត្រីជំនាញត្រួតពិនិត្យលើយានដ្ឋានជួសជុល និងយានដ្ឋានកែឆ្នៃតម្លើងយានយន្ត នៅទូទាំងប្រទេស ។

**ប្រការ ២** : ក្រុមមន្ត្រីជំនាញនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ពៅ ម៉ាលី** ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជា អគ្គនាយករង ប្រធាន

២-លោកស្រី **ឥម នីថារ៉ា** អគ្គនាយករង អនុប្រធាន

៣-លោក **ព្រាប ច័ន្ទវិបុល** អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សមាជិក

៤-លោក **ឌុយ ច័ន្ទដារ៉ា** អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សមាជិក

៥-លោក **តាំង ពៅ** ប្រធានការិ.ត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត សមាជិក

៦-លោក **ស្វ ពិសី** អនុប្រធានការិ.ស្ថិតិ និងស្រាវជ្រាវ សមាជិក

៧-លោក **ឃិត ច័ន្ទតារា** មន្ត្រីត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត សមាជិក

៨-មន្ត្រីជំនាញមួយចំនួនទៀតតាមការចាំបាច់ សមាជិក

**ប្រការ ៣** : ក្រុមមន្ត្រីជំនាញនេះ មានភារកិច្ចដូចខាងក្រោម :

១-ចុះត្រួតពិនិត្យយានដ្ឋានជួសជុល និងយានដ្ឋានកែឆ្នៃតម្លើងយានយន្ត នៅទូទាំងប្រទេស ដោយសហការជាមួយក្រុមមន្ត្រីជំនាញរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ធ្វើការត្រួតពិនិត្យយានដ្ឋានណាមួយដែលមានភាពមិនប្រក្រតីកើតឡើង ។

២-ធ្វើរបាយការណ៍ ពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

៣-រៀបចំនិងបង្កើតឡើងនូវបែបបទ និងគោលការណ៍សំរាប់ធ្វើការវិភាគ និងវាយតម្លៃព័ត៌មាន ដែលប្រមូលបានពីគ្រប់មជ្ឈដ្ឋានទាំងអស់ និងធានាបាននូវសុក្រឹត្យភាព និងសុច្ចរិតភាពនៃយានដ្ឋាន ដែលបានធ្វើការត្រួតពិនិត្យ ។

៤-ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ បទបញ្ជា សេចក្តីសម្រេច និងលិខិតបទដ្ឋានានា ពាក់ព័ន្ធនិងយានដ្ឋាន ។

៥-សម្របសម្រួល និងសហការជាមួយក្រុមមន្ត្រីជំនាញរបស់មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ដើម្បីប្រមូលនិងផ្លាស់ប្តូរព័ត៌មានគ្នាសំដៅបង្ការនិងទប់ស្កាត់ឱ្យបាននូវបទល្មើសយានដ្ឋាន និងសំដៅជំរុញការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពខ្ពស់ ។

៦-ទទួលអនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងទៀត ដែលអគ្គនាយកដ្ឋានដឹកជញ្ជូន និងក្រសួងសាធារណការ និងដឹកជញ្ជូនប្រគល់ជូន ។

**ប្រការ ៤** : រាល់ពេលចុះត្រួតពិនិត្យ ក្រុមមន្ត្រីជំនាញចុះត្រួតពិនិត្យលើយានដ្ឋាន ត្រូវមានលិខិតបញ្ជាបេសកកម្ម ។

**ប្រការ ៥** : ក្រុមមន្ត្រីជំនាញនេះ និងក្រុមមន្ត្រីជំនាញរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវសហការគ្នាឱ្យការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែឆ្នៃតម្លើងយានយន្តប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

**ប្រការ ៦** : នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកដឹកជញ្ជូន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត និងអស់លោក ដែលមានឈ្មោះក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ត្រាំ អ៊ីវតឹក**

**ចម្លងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-សាលារាជធានី ខេត្ត

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៦

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១១៤/០៨

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩

## ប្រកាស
## ស្តីពីការបង្កើតក្រុមការងារទេសចរណ៍ត្រួតពិនិត្យសកម្មភាពសេវាកម្សាន្តទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃ ទី ១០ ខែ មីនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃ ទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ .
- បានឃើញអនុក្រឹត្យលេខ ១០៧អនក្រ-បកចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៤សរ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីវិធានការទប់ស្កាត់ និងបង្រ្កាបសកម្មភាព " ក្មេងទំនើង " ។

## សម្រេច

**ប្រការ ១** : ត្រូវបានបង្កើត ក្រុមការងារទេសចរណ៍ត្រួតពិនិត្យសកម្មភាពសេវាកម្សាន្តទេសចរណ៍ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | លោក | **រស់ សិរីវ៉ា** | អគ្គនាយករងទេសចរណ៍ | ប្រធាន |
| ២- | លោក | **ត្នូច វ័ណ្ណៈ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | អនុប្រធាន |
| ៣- | លោក | **អ៊ុំ ផល្លី** | អធិការរង | អនុប្រធាន |

អគារលេខ ៦៣ ផ្លូវ៣៤៨ សង្កាត់ទួលស្វាយព្រៃ ២ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ២១៣ ៧៤១ ទូរសារ: +៨៥៥ ២៣ ២២០ ៧០៤ E-mail: admin@mot.gov.kh Website: www.mot.gov.kh

| | | | |
|---|---|---|---|
| ៤- លោក | **ប្រធានមន្ទីរទេសចរណ៍រាជធានី - ខេត្ត** | | សមាជិក |
| ៥- លោក | **ប្រធានការិយាល័យទេសចរណ៍ក្រុង-ខណ្ឌ-ស្រុក** | | សមាជិក |
| ៦- លោក | **ឡុង ផល្លីតា** | នាយរងការិយាល័យភោជនីយដ្ឋាន | សមាជិក |
| ៧- លោក | **សូ វិណា** | នាយរងការិយាល័យសណ្ឋាគារ | សមាជិក |
| ៨- លោកស្រី | **ថ្វាំ សុភារិន** | មន្ត្រីការិយាល័យសណ្ឋាគារ | លេខាធិការ |
| ៩- លោក | **សុត្ថារិន សុខឌ្ឍនា** | មន្ត្រីការិយាល័យភោជនីយដ្ឋាន | សមាជិក |
| ១០- លោក | **កែវ ច័ន្ទប្រាជ្ញា** | ជំនួយការ**ឯកឧត្តម ស៊ឹម សួង** | សមាជិក |
| ១១- លោក | **ហ៊ុន សុធា** | មន្ត្រីការិយាល័យភ្នាក់ងារទេសចរណ៍ | សមាជិក |

**ប្រការ ២** : ក្រុមការងារទេសចរណ៍ត្រួតពិនិត្យសកម្មភាព សេវាកម្មកម្សាន្តទេសចរណ៍មានមុខងារ និងភារកិច្ចដូចតទៅ :

- ចុះស្រង់ព័ត៌មាន ប្រមូលទិន្នន័យ រៀបចំស្ថិតិ និងធ្វើការត្រួតពិនិត្យរាល់សកម្មភាពអាជីវកម្មសេវាកម្មកម្សាន្តទេសចរណ៍ដូចជាប្រភេទសេវាកម្ម :ការ៉ាអូខេ ម៉ាស្សា ស្ប៉ា ស្ទីប រង្គសាល ឌីស្កូតែក បៀរហ្គាឌិន ក្លឹបកម្សាន្ត មណ្ឌលកម្សាន្ត និងសេវាកម្មកម្សាន្តផ្សេងៗទៀត មុនបង្អស់នៅរាជធានីភ្នំពេញ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីរទេសចរណ៍ ការិយាល័យទេសចរណ៍ខណ្ឌ ស្រុក ផ្នែកឯកជន ដើម្បីក្តាប់ព័ត៌មាន និងត្រួតពិនិត្យពីសកម្មភាពធ្វើអាជីវកម្មសេវាកម្មកម្សាន្តទេសចរណ៍ ដោយរកឱ្យឃើញ និងធ្វើបញ្ជីបែងចែក(**Classement**)មូលដ្ឋានសេវាកម្មកម្សាន្តដែលអនុវត្តបានល្អតាមការណែនាំរបស់រដ្ឋ និងមូលដ្ឋានអាជីវកម្មណាដែលអនុវត្តមិនទាន់បានល្អ
- លើកឡើងផែនការ វិធានការអប់រំកែលំអ និងវិធានការដាក់ស្តែងតាមច្បាប់ ។

**ប្រការ ៣** : ក្រុមការងារទេសចរណ៍ស្រង់ព័ត៌មានស្ថិតិ និងពិនិត្យសកម្មភាពសេវាកម្មកម្សាន្តទេសចរណ៍ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ រៀងរាល់សប្តាហ៍ ឱ្យបានទៀងទាត់។

**ប្រការ ៤** : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ថវិការបស់ក្រសួង ។

**ប្រការ ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលារាជធានី-ខេត្ត ដើម្បីសហការ
- គ្រប់មន្ទីរទេសចរណ៍រាជធានី-ខេត្ត ដើម្បីអនុវត្ត
- ប្រការ ១ និង ៥ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**ថោង ខុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីឌ្រីមស៍ អេនជីនារីង**
SIDREAMS ENGINEERING Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12935/08P ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៨
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក KIM YONG WOO

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៦ ផ្លូវលេខ ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូនសំបុត្រ និងកញ្ចប់ទំនិញ
-សេវាយកក់វែរជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រផលិតអំពូលអគ្គីសនី សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១០៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស ឌី ខេ អេនជីនារីង**

**SDK ENGINEERING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12934/08P ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក YUN SEOKYUN ប្រធានក្រុមប្រឹក្សាភិបាល

លោក KIM SANG BOK អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៦ ផ្លូវលេខ ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកា[illegible] សេ[illegible]ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រផលិតអំពូលអគ្គីសនី សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**ភឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១០៤ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេម អ៊ី អេស ធី អ៊ីមផត អិចផត**
**CAM EST IMPORT EXPORT Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5463/08E ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក MEIER JAAK ប្រធានក្រុមប្រឹក្សាភិបាល
លោក KOSKINEN TIMO OLAVI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៨៨A ផ្លូវឯករាជ្យ សង្កាត់លេខ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្មៈទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

គីម-ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងព្រះសីហនុ
- មន្ទីរពាណិជ្ជកម្មក្រុងព្រះសីហនុ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **សិលា មាស អ៊ីមផត អិចផត**

**SELA MEAS IMPORT EXPORT Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12929/08P** ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ក់ ចាន់គិរុណា** ប្រធានក្រុមប្រឹក្សាភិបាល

កញ្ញា **ម៉ក់ ចាន់គន្ធី** អភិបាល

លោកស្រី **ជា ស៊ីណាត** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៣៨ ផ្លូវលេខ ២៧១ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្មៈទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -ពិសេស ទិញ លក់ គ្រឿងសំណង់គ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូនអ្នកដំណើរ និងទំនិញ

-សេវាយកក់វិក្ជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**គឹម ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**

**លេខ** ៦១១៣ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **" ដូ ព្យុង អេឃ្វីបមេន "**
**" Do Pyeng Equipment Co., Ltd "**

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន " ដូ ព្យុង អេឃ្វីបមេន "**
**Branch Of " Do Pyeng Equipment Co., Ltd "**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 499/08B** ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

២- អភិបាលសាខាក្រុមហ៊ុន : លោក HYO KEUN WANG " តតិយជន "

៣- ទីស្នាក់ការសាខា : អាគារ IOC លេខ ២៥៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៤- កម្មវត្ថុអាជីវកម្ម : -អាហារណា នីហារណា ទិញ លក់ ទំនិញគ្រប់ប្រភេទ ពិសេស ទិញ លក់ ជួល តម្លើង និងជួសជុលសំភារៈបរិក្ខារសំណង់គ្រប់ប្រភេទ

៥- សញ្ជាតិក្រុមហ៊ុន : កូរ៉េ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលសាខាមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម្លងជូនៈ**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម

**គឹម_ស៊ីថន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១៧២ ពណ.ចបព

ភ្នំពេញថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បាយ័ន ស៊ីស្ទឹម**

**BAYON SYSTEMS Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 5461/08E** ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
- លោក KANG SUNG HO ប្រធានក្រុមប្រឹក្សាភិបាល
- លោក KIM GWANG SOO អភិបាល
- លោក JEONG SEOK YEONG អភិបាល
- លោក JUNG YOUNG CHEOL "តតីយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៤៩ BEo ផ្លូវលេខ ៤៣០ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -លក់ដុំ និងលក់រាយទំនិញគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្នែកពត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - បញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ -ដាំដំណាំកៅស៊ូ ដាំដើមអាកាស្យា កសិដ្ឋាន ចិញ្ចឹម គោ ជ្រូក
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ៚

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋមន្ត្រីស្តីទី**

**គឹម_ស៊ីថន**

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១៣៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេ ធី ធី អេ - ស្ត្រាក់ឆឺរ៉ល អេនជីនារីង & ខនសាល់ធីង**

**ATTA - STRUCTURAL ENGINEERING & CONSULTING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5457/08E ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ZAZWORKA THOMAS

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣២ ភូមិតាក្តុល ឃុំតាក្តុល ស្រុកតាខ្មៅ ខេត្តកណ្តាល

៥- កម្មវត្ថុអាជីវកម្ម : -មជ្ឈមណ្ឌលពាណិជ្ជកម្ម និងផ្សារទំនើប

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្នែកពត៌មានវិទ្យា

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវា[illegible]ទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ថេរវេលា : -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១៣៤ ពណ.ចបព

ភ្នំពេញថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៊ី អិល ខេ អ៊ិនវេសមេន ខូ អិលធីឌី**

**BLK INVESTMENT CO., LTD**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5468/08E ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក BANG JOOMIN ប្រធានក្រុមប្រឹក្សាភិបាល

លោក LEE JONG HO អភិបាល

លោក KIM DONGIN អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦ D ផ្លូវលេខ ២៣០ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកបរិក្ខារពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម